# ផ្លូវបំបែក

## ការសិក្សាអំពីផ្នត់គំនិតសង្គមលើការចែកផ្លូវគ្នា ការលែងលះ និងសិទ្ធិស្ត្រីនៅកម្ពុជា

ការស្រាវជ្រាវបែបចូលរួមផ្អែកលើ
គោលការណ៍លទ្ធិស្ត្រីនិយម

ឆ្នាំ២០២៣

ក្លាហាន
klahaan
brave

ការស្រាវជ្រាវនេះសម្រេចបានដោយជោគជ័យដោយសារមានការគាំទ្រមូលនិធិសប្បុរសពីម្ចាស់ជំនួយរបស់យើង។

# មាតិកា


## ១.
## សេចក្តីផ្តើម

១.១ សង្ខេបរបកគំហើញ

## ២.
## វិធីសាស្ត្រស្រាវជ្រាវ

## ៣.
## គួរលែងលះ ឬ មិនគួរលែងលះ៖ ឧបសគ្គ និងកត្តាជំរុញ

៣.១ មូលហេតុដែលជំរុញឲ្យស្ត្រីសម្រេចចិត្តលែងលះ

៣.២ មូលហេតុដែលស្ត្រីមិនអាចលែងលះបាន

## ៤.
## មធ្យោបាយលែងលះ៖ នីតិវិធីបែបបិតាធិបតេយ្យ

៤.១ អាពាហ៍ពិពាហ៍ស្របច្បាប់

៤.២ អាពាហ៍ពិពាហ៍ក្រៅផ្លូវការ/បែបប្រពៃណី

៤.៣ ស្ថានភាពខុសគ្នានៃប្រជាសាស្ត្រ

៤.៤ ស្ថានភាពជីវិតក្រោយការលែងលះ

## ៥.
## បរិបទសង្គម... ហាក់មានការផ្លាស់ប្តូរផ្នត់គំនិតជុំវិញការលែងលះ

## ៦.
## សេចក្តីសន្និដ្ឋាន

## ក្រុមការងារក្លាហាន

ប៊ុណ្យ រចនា
Kate Seewald
Jade Sainte-Rose
ពេជ្រ ភារ័ក្ស
គាំ ណាទីតសារ៉ា

## សមាជិកក្រុមអ្នកស្រាវជ្រាវសកម្មនៅមូលដ្ឋាន

ឌិន លីសីណែត
វ៉ែន រ៉ូលីន
វ៉ន ពេជ្រចាន់សីលា
ស៊ុត សិរី
ហុង សុភ័ក្រ្តរឌ្ឍនៈ

យើងសូមថ្លែងអំណរគុណចំពោះអ្នកដែលបានចូលរួមក្នុងគម្រោងនេះ ដែលបានចំណាយពេលវេលាដ៏មានតម្លៃរបស់ពួកគេដើម្បីធ្វើឱ្យការស្រាវជ្រាវនេះប្រព្រឹត្តទៅដោយជោគជ័យ។ ទាំងនេះរួមមានទាំងអ្នកតបសម្ភាស៍ដែលធ្លាប់ឆ្លងកាត់ការលែងលះ និងអ្នកដែលមិនបានធ្លាប់ឆ្លងកាត់ការលែងលះដែលបានចែករំលែកការយល់ឃើញយ៉ាងទូលំទូលាយលើប្រធានបទ ក៏ដូចជាអ្នកឯកទេសសិទ្ធិស្ត្រីនៅរាជធានីភ្នំពេញផងដែរ។

ក្រុមការងារ ក្លាហាន ក៏សូមថ្លែងអំណរគុណជាពិសេស និងកោតសរសើរចំពោះក្រុមស្រាវជ្រាវសកម្មនៅមូលដ្ឋាន។ អ្នកស្រាវជ្រាវក្នុងស្រុកទាំងនេះបានចំណាយពេលវេលា ការប្តេជ្ញាចិត្ត ពោពេញដោយថាមពលក្នុងការធ្វើឲ្យបទពិសោធន៍នៃការស្រាវជ្រាវនេះកាន់តែមានមានភាពស៊ីជម្រៅ។

# ១

# សេចក្ដីផ្ដើម



# ១. សេចក្តីណែនាំ

នៅប្រទេសកម្ពុជាក៏ដូចជាបណ្តាប្រទេសនានាក្នុងសកលលោក ការលែងលះអាចជាជម្រើសដ៏ចម្រូងចម្រាសមួយ។ អាពាហ៍ពិពាហ៍នៅតែជាជម្រើសដែលពេញនិយមបំផុតនៅកម្ពុជា ជាក់ស្តែង មានប្រជាជនខ្មែរក្នុងវ័យ ៣០ឆ្នាំ តិចជាង៦% តែប៉ុណ្ណោះដែលមិនធ្លាប់រៀបការទាល់តែសោះ[១]។ ពិធីមង្គលការគឺជាពិធីដ៏សំខាន់មួយសម្រាប់បុរស និងស្ត្រី ក៏ជាការបង្ហាញឲ្យឃើញនូវវប្បធម៌ខ្មែរដោយប្រជាជនកម្ពុជាដែលរស់នៅក្នុងប្រទេស និងអ្នកដែលបានធ្វើចំណាកស្រុកនៅជុំវិញសកលលោក។ ក្រុមជនជាតិភាគតិច រួមមាន ជនជាតិខ្មែរឥស្លាម និងជនជាតិដើមភាគតិច ក៏បានផ្តល់ភាពសំខាន់ខ្លាំងលើអាពាហ៍ពិពាហ៍ ព្រមទាំងបានថែរក្សា និងផ្តល់តម្លៃខ្ពស់លើពិធីអាពាហ៍ពិពាហ៍តាមប្រពៃណីជាក់លាក់របស់ពួកគេផងដែរ។ សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា (LGBTQI+) នៅក្នុងប្រទេសកម្ពុជាបាននឹងកំពុងធ្វើយុទ្ធនាការដើម្បីទាមទារឲ្យមានសមភាពអាពាហ៍ពិពាហ៍ ដើម្បីធានានូវការទទួលបានសិទ្ធិមូលដ្ឋានរបស់ពួកគេ ហើយនេះក៏ជាការបង្ហាញអំពីសារៈសំខាន់នៃអាពាហ៍ពិពាហ៍ សម្រាប់បុគ្គលគ្រប់អត្តសញ្ញាណយេនឌ័រ និងនិន្នាការភេទ។ នៅក្នុងការសិក្សាស្រាវជ្រាវកន្លងមកនេះ ក្លាហានបានឈ្វេងយល់ពីសារៈសំខាន់នៃបទដ្ឋានសង្គមនានាទាក់ទងនឹងអាពាហ៍ពិពាហ៍ដូចជាព្រហ្មចារីយ៍ស្ត្រីមុនពេលរៀបការ ហើយរបកគំហើញក៏បានចង្អុលបង្ហាញថាបទដ្ឋានទាំងនេះនៅតែមានឥទ្ធិពល ទោះបីជាក្នុងចំណោមយុវជនជំនាន់ ក្រោយក៏ដោយ។

ទោះជាយ៉ាងណា ផ្នត់គំនិតរួមក្នុងសង្គមដែលថា 'មួយជីវិតរៀបការតែម្តង' នៅតែបន្តរស់រាន្តនៅក្នុងសង្គម ទោះបីជាអំពើហិង្សាផ្អែកលើយេនឌ័រ ជាពិសេសអំពើរំលោភបំពានក្នុងចំណងអាពាហ៍ពិពាហ៍មានអាត្រាខ្ពស់ក៏ដោយ។ ការសិក្សាស្រាវជ្រាវដ៏ធំមួយធ្វើឡើងដោយ អង្គការសហប្រជាជាតិទទួលបន្ទុកលើស្ត្រី (UN Women) និងអង្គការសុខភាពពិភពលោក (WHO) នៅក្នុងឆ្នាំ២០១៥ បានរកឃើញថា ២០% នៃស្ត្រីកម្ពុជាបានជួបប្រទះអំពើហិង្សាផ្លូវកាយ និង/ឬផ្លូវភេទពីសំណាក់ដៃគូស្និទ្ធស្នាល នៅក្នុងទំនាក់ទំនងស្និទ្ធស្នាលឬអាពាហ៍ពិពាហ៍[២]។ ការពិតដែលអាពាហ៍ពិពាហ៍បង្កហានិភ័យដល់សុវត្ថិភាពផ្លូវកាយ និងសុខុមាលភាពរបស់ស្ត្រីជាច្រើននោះត្រូវបានចោទជាសំណួរថា តើការលែងលះនិងលទ្ធភាពទទួលបានការលែងលះជាបញ្ហា សិទ្ធិមនុស្ស ជាពិសេសសិទ្ធិស្ត្រីដោយរបៀបណា។ គួរកត់សម្គាល់ថាផងដែរថា បើទោះបីជាស្ត្រីនៅក្នុងប្រទេសកម្ពុជាជួបប្រទះនឹងការមាក់ងាយធ្ងន់ធ្ងរដោយសារការបែកបាក់អាពាហ៍ពិពាហ៍ក៏ដោយក៏ការលែងលះប្រហែលជា ៧០% ត្រូវបានផ្តួចផ្តើមឡើងដោយស្ត្រី [៣]។

ការសិក្សាស្រាវជ្រាវកន្លងមកដែលធ្វើឡើងនៅក្នុងប្រទេសផ្សេងៗបានរកឃើញថា អត្រានៃការធ្វើអត្តឃាតរបស់ស្ត្រីមានទិន្នាការធ្លាក់ចុះបន្ទាប់ពីការផ្ដល់នីតិភាពដល់ការលែងលះ ឬបន្ទាប់ពីការធ្វើសេរីភាវូបនីយកម្មនៃការលែងលះ[៤]។ ការសិក្សាស្រាវជ្រាវមួយដែលធ្វើឡើងក្នុងឆ្នាំ ២០០៣ នៅសហរដ្ឋអាមេរិកបានរកឃើញថា អត្រានៃការធ្វើអត្តឃាតរបស់ស្ត្រីមានការធ្លាក់ចុះយ៉ាងច្រើននៅតាមបណ្ដារដ្ឋដែលអនុម័តច្បាប់លែងលះជាឯកតោភាគី ដែលតួរលេខចុះមានប្រមាណជា ២០%។ ប៉ុន្តែគ្មានសញ្ញាណគួរកត់សម្គាល់ណាមួយ ត្រូវបានរកឃើញចំពោះការធ្វើអត្តឃាតរបស់បុរសនោះទេ[៥]។

ការសិក្សាដដែលនេះក៏បានរាយការណ៍ដែរថា “លទ្ធផលបង្ហាញពីការថយចុះយ៉ាងខ្លាំងនៃអំពើហិង្សាក្នុងគ្រួសារ ជាមួយនឹង ... ភ័ស្តុតាងបង្ហាញថាការលែងលះដោយឯកតោភាគីបាននាំឱ្យមានការថយចុះនៃចំនួនស្ត្រីដែលត្រូវបានសម្លាប់ដោយដៃគូស្និទ្ធស្នាលរបស់ពួកគេ។” ជាថ្មីម្ដងទៀត ទិន្នន័យមិនបានបង្ហាញពីផលប៉ះពាល់ដែលអាចមើលឃើញទៅលើករណីដែលបុរសត្រូវបានសម្លាប់ដោយដៃគូនោះទេ។ ក្នុងអំឡុងពេលដែលការពិភាក្សា និងជជែកដេញដោលអំពីនីតិវិធី និងក្របខណ្ឌច្បាប់ដែលកំពុងមានសុពលភាពនៅក្នុងប្រទេសកម្ពុជាទាក់ទងនឹងវិវាទអាពាហ៍ពិពាហ៍ ការចែកផ្លូវគ្នា និងការលែងលះដែលកំពុងតែកើតឡើង – ជាពិសេសការអនុវត្តន៍វិធានការសម្រុះសម្រួល ឬវិធានការដោះស្រាយវិវាទផ្សេងទៀតនោះ(ADR) – ការសិក្សាស្រាវជ្រាវនេះ ឈ្វេងយល់អំពីទស្សនៈសង្គមនាពេលបច្ចុប្បន្នអំពីការលែងលះ និងបង្ហាញពីបទពិសោធន៍នៃ ការលែងលះ។

ការសិក្សាស្រាវជ្រាវនេះប្រើប្រាស់ចក្ខុវិស័យសិទ្ធិស្ត្រីទៅត្រួតពិនិត្យមើលបញ្ហាសំខាន់ៗមួយចំនួនដូចជា៖

- កត្តាជំរុញទូទៅបំផុតដែលនាំស្ត្រីឱ្យស្វែងរកការលែងលះ
- ឧបសគ្គផ្នែកសង្គម វប្បធម៌ រដ្ឋបាល និងហិរញ្ញវត្ថុ ដែលស្ត្រីប្រឈមមុខនៅពេលស្វែងរកការលែងលះ និង
- ផលប៉ះពាល់រយៈពេលវែងនៃការលែងលះ – ទាំងវិជ្ជមាន និងអវិជ្ជមាន។

ការសិក្សានេះពិនិត្យមើលទៅលើបទពិសោធន៍ជីវិតរបស់អ្នកចូលរួមស្ត្រី និងបុរសដែលឆ្លងកាត់ការលែងលះដោយផ្ទាល់និងពិនិត្យមើលទៅលើការយល់ឃើញ និងទស្សនៈទូទៅរបស់អ្នកចូលរួមកម្ពុជាដែលមិនធ្លាប់ឆ្លង់កាត់ការលែងលះទៅលើប្រធានបទនេះផងដែរ។

ដោយអនុវត្តវិធីសាស្ត្រស្រាវជ្រាវបែបចូលរួមផ្អែកលើគោលការណ៍លទ្ធិស្ត្រីនិយម (FPAR) ការស្រាវជ្រាវនេះត្រូវបានសហការបង្កើតឡើងដោយសមាជិកសហគមន៍កម្ពុជាដែលមានបទពិសោធន៍ផ្ទាល់អំពីបញ្ហាពាក់ព័ន្ធ ដូចជាអ្នកដែលបានឆ្លងកាត់ការលែងលះដោយផ្ទាល់ ឬអ្នកដែលមានឪពុកម្ដាយលែងលះ។ ការសិក្សានេះផ្ដល់នូវមូលដ្ឋានភ័ស្តុតាងបឋមដែលជួយឲ្យអ្នកតស៊ូមតិផ្នែកសមភាពយេនឌ័រអាចយល់កាន់តែច្បាស់ និងអាចកែសម្រួលសារធ្វើឲ្យកិច្ចអន្តរាគមន៍របស់ពួកគេជុំវិញសមភាពក្នុងអាពាហ៍ពិពាហ៍កាន់តែមានប្រសិទ្ធភាព យល់កាន់តែច្បាស់អំពីទំនាក់ទំនងអំណាចដែលលេចឡើងក្នុងវិវាទអាពាហ៍ពិពាហ៍ និងសិទ្ធិបុគ្គលគ្រប់រូបក្នុងការចែកផ្លូវ ឬលែងលះពីប្ដីប្រពន្ធរបស់គេ។

# រចនាសម្ព័ន្ធរបាយការណ៍

សេចក្តីណែនាំនេះនឹងផ្តល់ការពន្យល់បន្ថែមនៅផ្នែកវិធីសាស្ត្រស្រាវជ្រាវ (ផ្នែកទី២) ដែលនឹងផ្តល់នូវព័ត៌មានលម្អិត និងចំណុចសំខាន់បន្ថែមទៀតអំពីវិធីសាស្ត្រ FPAR ដែលប្រើប្រាស់ក្នុងការសិក្សានេះ។ ក្នុងនោះដែរក៏បង្ហាញពីភាពជាក់លាក់ទាក់ទងនឹងទំហំនៃសំណាកការគិតគូរអំពីក្រមសីលធម៌នៃការស្រាវជ្រាវ និងការវិភាគតាមមូលបទផ្អែកលើទិន្នន័យជាក់ស្តែង។

ផ្នែកទី៣ គឺជាផ្នែកតំបូងគេនៃរបកគំហើញទាំង ៣ ផ្នែកនៃការសិក្សាស្រាវជ្រាវ។ ផ្នែកនេះពិនិត្យមើលបរិបទដែលស្ត្រីស្វែងរកការលែងលះដោយសិក្សាទៅលើ 'កត្តាជំរុញ' (មូលហេតុទូទៅដែលស្ត្រីស្វែងរកការលែងលះ) និង 'ឧបសគ្គ' (មូលហេតុទូទៅដែលស្ត្រីមិនអាចលែងលះបាន ឬចុងក្រោយសម្រេចចិត្តមិនបន្តការលែងលះ)។

ផ្នែកទី៤ ពិនិត្យកាន់តែស៊ីជម្រៅទៅលើបទពិសោធន៍ជាក់ស្តែងរបស់ស្ត្រីនៅក្នុងដំណើរការនៃនីតិវិធីលែងលះ និងការយល់ឃើញរបស់ពួកគេអំពីគុណភាព និងសុខុមាលភាពជីវិតរបស់ពួកគេក្រោយការលែងលះ។ ផ្នែកនេះរួមបញ្ចូល មូលបទដូចជា ការបង្ខំឲ្យធ្វើការផ្សះផ្សា ដែលជាបញ្ហាប្រឈមសម្រាប់អ្នកដែលរៀបការបែប 'ប្រពៃណី' ឬ 'មិនផ្លូវការ'។ ផ្នែកនេះក៏ពិនិត្យមើលដែរថា តើកត្តាប្រជាសាស្ត្រដូចជា អ្នកជនបទ/ទីក្រុង ឬភាពខុសគ្នានៃជំទាន់ជះឥទ្ធិពលដូចម្តេចទៅលើផ្នត់គំនិតជុំវិញការលែងលះ។

ផ្នែកទី៥ ពិនិត្យមើលថាតើសាធារណៈជនយល់ឃើញដូចម្តេចដែរចំពោះការលែងលះនៅកម្ពុជានាពេលបច្ចុប្បន្ននេះ ហើយផ្នែកទី៦ ផ្តល់សេចក្តីសន្និដ្ឋានសរុបរបស់គម្រោងសិក្សាស្រាវជ្រាវនេះ។

## សំណួរស្រាវជ្រាវ៖

ក្រុមស្រាវជ្រាវបានបង្កើតសំណួរខាងក្រោមជាមគ្គុទេសដឹកនាំការស្រាវជ្រាវ៖

១. កត្តាអ្វីខ្លះដែលជំរុញឲ្យមានការលែងលះ? ហេតុអ្វីបានជាគេធ្វើការលែងលះ? តើយេនឌ័រមានឥទ្ធិពលអ្វីខ្លះ លើមូលហេតុទាំងអស់នេះ?

២. តើស្ត្រីជួបឧបសគ្គអ្វីខ្លះពេលដែលស្វែងរកការលែងលះ? បើប្រៀបធៀបជាមួយបុរស តើឧបសគ្គទាំងអស់នេះ ខុសគ្នាដែរឬទេ?

៣. តើនាពេលបច្ចុប្បន្ននេះ សង្គមកម្ពុជាយល់ឃើញយ៉ាងណាដែរទៅលើការលែងលះ?
   ក. តើផ្នត់គំនិតនេះមានលក្ខណៈខុសគ្នាដូចម្តេចផ្អែកលើកត្តាយេនឌ័រ អាយុ និងភូមិសាស្ត្រ?

   ខ. តើផ្នត់គំនិតទាំងអស់នេះបង្កផលប៉ះពាល់ដូចម្តេចទៅលើសិទ្ធិស្ត្រី និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ស្ត្រី?

   គ. តើការផ្លាស់ប្តូរអ្វីខ្លះបានកើតឡើងចំពោះជីវិតស្ត្រីក្រោយពេលលែងលះ? តើការផ្លាស់ប្តូរនេះមានលក្ខណៈខុសគ្នាពីបុរសដែរទេ?

# ១.១ សង្ខេបរបកគំហើញ

១. ដូចគ្នានឹងការរងនូវសម្ពាធពីក្រុមគ្រួសារឲ្យបន្តជីវិតអាពាហ៍ពិពាហ៍ ស្ត្រីដែលស្វែងរក ឬបានលែងលះនៅក្នុងប្រទេសកម្ពុជាត្រូវទទួលរងនូវ ភាពអាម៉ាស់ និងការវិនិច្ឆ័យ យ៉ាងធ្ងន់ធ្ងរពីសង្គម។ អ្នកចូលរួមស្ទង់មតិអនឡាញចំនួន ៨៧% រាយការណ៍អំពីជំនឿដែលថាស្ត្រីត្រូវរងភាពអាម៉ាស់ ឬការមាក់ងាយក្រោយការលែងលះខ្លាំងជាងបុរស។ ផ្ទុយមកវិញ មានអ្នកចូលរួមត្រឹមតែ ១% ប៉ុណ្ណោះ ដែលគិតថាបុរសទទួលរងផលប៉ះពាល់ច្រើនជាងស្ត្រី (ភាគរយនៃអ្នកចូលរួមផ្សេងទៀតជឿថា បុគ្គលទាំងពីរភេទរងនូវភាពអាម៉ាស និងការវិនិច្ឆ័យដូចគ្នា)។

២. ‘កត្តាជំរុញទូទៅ’ ដែលនាំឲ្យមានការលែងលះ (មូលហេតុដែលស្ត្រីស្វែងរកការលែងលះ) ចែករំលែកដោយអ្នកចូលរួមនៅក្នុងការសិក្សានេះរួមមាន អំពើហិង្សាបង្កឡើងដោយដៃគូស្និទ្ធស្នាល (ជាទូទៅគឺជាបណ្តុំនៃអំពើហិង្សា រួមមានហិង្សាផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និង/ឬអំពើហិង្សាផ្នែកសេដ្ឋកិច្ច) ការប្រើប្រាស់គ្រឿងស្រវឹង និងការញៀនល្បែង ការមិនអាចបំពេញតាមការរំពឹងទុកផ្នែកយេនឌ័រ ការឈ្លោះប្រកែកគ្នា និងអំពើផិតក្បត់។

៣. ‘ឧបសគ្គទូទៅ’ ដែលរារាំងការទទួលបានការលែងលះ (មូលហេតុទូទៅដែលស្ត្រីមិនអាច ឬបង្វែងមិនឲ្យទទួលបានការលែងលះ) ចែករំលែកដោយអ្នកចូលរួមនៅក្នុងការសិក្សានេះ រួមមាន ភាពអាម៉ាស់ និងការវិនិច្ឆ័យដោយ ក្រុមគ្រួសារ ឬសង្គម កង្វះការអប់រំ និងព័ត៌មានអំពីនីតិវិធីលែងលះ ការយល់ឃើញអំពីផលប៉ះពាល់អវិជ្ជមានទៅលើ កូនៗក្រោយការលែងលះ និង វប្បធម៌ព្រហ្មចារីដែលចាក់ឫសរឹងមាំនៅក្នុងសង្គមដែលមាក់ងាយស្ត្រីដែលមានដៃគូផ្លូវភេទលើសពីម្នាក់ក្នុងមួយជីវិត។

៤. អ្នកចូលរួមសម្ភាសន៍បានរាយការណ៍ថាការលែងលះរបស់ពួកគេ បានបង្កផលប៉ះពាល់យ៉ាងខ្លាំងមកលើជីវិតរបស់ពួកគេ ទោះជាកន្លងផុតច្រើនឆ្នាំទៅក៏ដោយ។ ផលប៉ះពាល់អវិជ្ជមាន ដែលត្រូវបានរាយការណ៍ជាទូទៅរួមមាន ភាពអាម៉ាស់ និងការមាក់ងាយ ការប៉ះទង្គិចផ្លូវចិត្ត និងការបាក់ស្បាត ផលប៉ះពាល់អវិជ្ជមានលើកូនៗ និងជារឿយៗផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច។ ផលប៉ះពាល់ជាវិជ្ជមាន រួមមាន សេរីភាពពីអំពើហិង្សា និងអំពើរំលោភបំពាន ការថយចុះនៃបន្ទុកការថែទាំគ្មានប្រាក់កម្រៃសម្រាប់អតីតស្វាមី ទំនាក់ទំនងជាមួយកូនមានភាពល្អប្រសើរ និងការកើនឡើងនៃស្វ័យភាព និងសេរីភាពផ្ទាល់ខ្លួន។

៥. ស្ត្រីជនបទដែលឆ្លងកាត់ការលែងលះត្រូវបានគេយល់ឃើញថាបានទទួលរងផលប៉ះពាល់ដោយការមាក់ងាយ និងការវិនិច្ឆ័យក្នុងសង្គមច្រើន។ ៤៨% នៃអ្នកឆ្លើយតបការស្ទង់មតិអនឡាញ យល់ឃើញថាស្ត្រីជនបទរងផលប៉ះពាល់ច្រើនជាងស្ត្រីនៅទីក្រុង។ ផ្ទុយមកវិញមានតែ ៨% នៃអ្នកចូលរួមតែប៉ុណ្ណោះ ដែលមានអារម្មណ៍ថាស្ត្រីនៅទីក្រុងរងផលប៉ះពាល់ច្រើនជាងស្ត្រីជនបទ (មានអ្នកចូលរួមចំនួន ៤៤% បានរាយការណ៍ថាមិនមានភាពខុសគ្នារវាងពួកគេទេ) ។

៦. គេយល់ឃើញថា ស្ត្រីទទួលរងផលប៉ះពាល់ផ្លូវអារម្មណ៍ពីការលែងលះខ្លាំងជាងបុរស។ ៦៣% នៃអ្នកឆ្លើយតបការស្ទង់មតិអនឡាញបានបង្ហាញថា "ជាធម្មតាស្ត្រីទទួលរងផលប៉ះពាល់ច្រើនជាង" ហើយមានតែ ១% ប៉ុណ្ណោះដែលមានអារម្មណ៍ថាបុរសជាធម្មតារងផលប៉ះពាល់ច្រើនជាង។ ៣៦%បានរាយការណ៍ថាមិនមានភាពខុសគ្នាទេ។

៧. គេយល់ឃើញថា ស្ត្រីទទួលរងផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុក្រោយការលែងលះច្រើនជាងបុរស។ ៦៦% នៃអ្នកឆ្លើយតបការស្ទង់មតិអនឡាញបានបង្ហាញថា "ជាធម្មតាស្ត្រីរងផលប៉ះពាល់ច្រើនជាង" បើប្រៀបធៀបទៅនឹងបុរសមានតែ ៣% ប៉ុណ្ណោះ។ ២៦% បានរាយការណ៍ថាមិនមានភាពខុសគ្នាទេ ខណៈដែល ៥% យល់ថាជាធម្មតាភាគីទាំងពីរមិនរងផលប៉ះពាល់ទេ។

៨. គេយល់ឃើញថាមនុស្សវ័យចំណាស់ទំនងជានឹងធ្វើការវិនិច្ឆ័យទៅលើអ្នកដែលលែងលះ។ ៥៨% នៃអ្នកឆ្លើយតបការស្ទង់មតិអនឡាញ បានជ្រើសរើសមនុស្សវ័យចំណាស់ (៤០+) ថាជាអ្នកវិនិច្ឆ័យច្រើនលើការលែងលះ ធៀបនឹង ១៧% សម្រាប់មនុស្សវ័យក្មេង (ក្មេងជំនាន់ក្រោយ និងមនុស្សវ័យកណ្តាល)។ ២៥% បានរាយការណ៍ថា មិនមានភាពខុសគ្នាទេ។

៩. ការលែងលះត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ទាំងស្រុងថានៅតែជាជម្រើសជីវិតដ៏ចម្រូងចម្រាសមួយនៅក្នុងប្រទេសកម្ពុជាជាពិសេសសម្រាប់ស្ត្រី។ ទោះជាយ៉ាងណាក៏ដោយ ផ្នត់គំនិតសង្គមចំពោះការលែងលះ ត្រូវបានគេមើលឃើញថា មានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ទៅតាមបរិបទសង្គម និងនៅក្នុងចំណោមមនុស្សគ្រប់ជំនាន់ ដោយមើលឃើញថាសេរីភាពជុំវិញការលែងលះហាក់ដូចជាកើនឡើងច្រើន។ ជាក់ស្តែងនៅពេលសួរថាតើផ្នត់គំនិតសង្គមចំពោះការលែងលះមានការផ្លាស់ប្តូរដែរឬទេ បើប្រៀបធៀបទៅនឹងឆ្នាំ២០០០។ ការឆ្លើយតបជារួមយ៉ាងច្រើនរហូតដល់ ៨៩% នៃអ្នកចូលរួមស្ទង់មតិអនឡាញលើកឡើងថា ប្រជាជនទទួលយកការលែងលះកាន់តែច្រើនជាងមុន។ មានតែ២%ប៉ុណ្ណោះដែលរាយការណ៍ថាប្រជាជនហាក់កាន់តែមិនទទួលយកការលែងលះ ខណៈដែល ៨% បានបង្ហាញភាពមិនច្បាស់លាស់ និង ១% មានអារម្មណ៍ថាគ្មានការផ្លាស់ប្តូរផ្នត់គំនិតទេចំពោះការលែងលះនោះទេ។

# ២

# វិធីសាស្ត្រស្រាវជ្រាវ



# ២. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះបានអនុវត្តធីសាស្ត្រស្រាវជ្រាវសកម្មផ្អែកលើគោលការណ៍លទ្ធិស្ត្រីនិយម (FPAR) ទាំងនៅក្នុងការរចនានិងដំណើរការស្រាវជ្រាវទាំងស្រុង។ យោងតាមAPWLD ដែលជាស្ថាប័នបង្កើតវិធីសាស្ត្រស្រាវជ្រាវ FPAR នៅក្នុងតំបន់ FPARគឺជាវិធីសាស្ត្រនៃការស៊ើបអង្កេតបញ្ហាសង្គមដែលមានការចូលរួមដោយផ្ទាល់ពីសំណាក់ជនរងគ្រោះ នៃអំពើជិះជាន់ និងប្រជាពលរដ្ឋក្នុងសហគមន៍ ដើម្បីកំណត់បញ្ហា និងស្វែងរកដោះស្រាយ។

FPAR ជា "មធ្យោបាយមួយដែលអ្នកស្រាវជ្រាវនិងអ្នកចូលរួមស្រាវជ្រាវបានសហការគ្នាធ្វើសកម្មភាពរួមទាំងសកម្មភាព រយៈពេលខ្លីនិងរយៈពេលវែងដើម្បីការផ្លាស់ប្តូរសង្គម" [៦]។ FPAR ក៏រួមបញ្ចូលយ៉ាងហ្មត់ចត់នូវទស្សនៈ និងដំណើរការស្រាវជ្រាវផ្អែកលើគោលការណ៍ស្ត្រីនិយម ការកសាងសមត្ថភាព ក៏ដូចជាការចែករំលែកចំណេះដឹងផងដែរ។ ក្នុងន័យនេះ ក្រុមអ្នកស្រាវជ្រាវសកម្មដែលមានបទពិសោធន៍ជីវិតឆ្លងកាត់ការលែងលះ (ទាំងស្ត្រីដែលលែងលះគ្នាដោយខ្លួនឯង ឬស្ត្រីដែលមានឪពុកម្តាយលែងលះ) បានចូលរួមសហការរចនាគម្រោងសិក្សាស្រាវជ្រាវ។

ក្រុមអ្នកស្រាវជ្រាវសកម្មដែលជាអ្នកស្ម័គ្រចិត្តដែលកំពុងរស់នៅទីក្រុងភ្នំពេញនិងខេត្តកែប បានទទួលការបណ្តុះបណ្តាល អំពីក្រមសីលធម៌គោលការណ៍ស្រាវជ្រាវ បច្ចេកទេសប្រមូលទិន្នន័យ និង បានចូលរួមនៅក្នុងដំណើរការនៃការសិក្សា ស្រាវជ្រាវទាំងស្រុង។

# កូដនីយកម្ម និងការវិភាគ

វិធីសាស្ត្រគុណវិស័យគឺជាវិធីសាស្ត្រចម្បងសម្រាប់ការសិក្សាស្រាវជ្រាវដែលក្នុងនោះអ្នកស្រាវជ្រាវបានសម្ភាសន៍អ្នកចូលរួមស្ត្រី និងបុរសដោយផ្អែកលើកម្រងសំណួរដែលអាចបត់បែនបាន ហើយអនុញ្ញាតឱ្យពួកគេមានឱកាសពិភាក្សាឲ្យកាន់តែស៊ីជម្រៅ។ ការសម្ភាសន៍គុណវិស័យចំនួន៤០ បានធ្វើឡើងនៅក្នុងទីក្រុងភ្នំពេញ តំបន់ជនបទនៃខេត្តរតនគិរី និងខេត្តកែប និងត្រូវបានបំពេញបន្ថែមដោយទិន្នន័យពីការស្ទង់មតិអនឡាញ។

ផ្អែកលើសំណួរស្រាវជ្រាវ និងប្រភេទនៃកម្រងសំណួរ ក្រុមអ្នកស្រាវជ្រាវបានសម្រេចចិត្តជ្រើសរើសក្រុមស្ត្រីដែលឆ្លងកាត់ការលែងលះជាក្រុមអ្នកសម្ភាសន៍សំខាន់ជាងគេ(២២ក្នុងចំណោម៤០)។ នេះដោយសារតែការស្រាវជ្រាវព្យាយាមឈ្វេងយល់ពីបទពិសោធន៍របស់ស្ត្រីខ្មែរដែលឆ្លងកាត់ការលែងលះ–ជាក្រុមដែលមិនសូវមានគេសិក្សាស្រាវជ្រាវពីមុនមក –ដោយប្រើចក្ខុលទ្ធិស្ត្រីនិយម និងដើម្បីបន្លឺសម្លេងរបស់ពួកគេ។

| អ្នកចូលរួមសម្ភាសន៍ | ចំនួន | កូដ |
|---|---|---|
| ស្ត្រីមានបទពិសោធន៍លែងលះ | ២២ | DW |
| បុរសមានបទពិសោធន៍លែងលះ | ៣ | DM |
| ស្ត្រីមិនមានបទពិសោធន៍លែងលះ | ៥ | NDW |
| បុរសមិនមានបទពិសោធន៍លែងលះ | ៥ | NDM |
| បុគ្គលិកអង្គការសង្គមស៊ីវិល | ៥ | CW |
| សរុប | ៤០ | |

ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីឲ្យយល់កាន់តែច្បាស់ពីផលប៉ះពាល់ខុសគ្នានៃស្ថានភាពមាក់ងាយក្នុងសង្គម និងថា តើស្ថានភាពនេះកើតឡើងខុសគ្នារបៀបម៉េចរវាងបុរសនិង ស្ត្រីនោះ បុរសដែលឆ្លងកាត់ការលែងលះមួយចំនួន (៣) ក៏ត្រូវបានជ្រើសរើសដើម្បីចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេផងដែរ។ ក្រុមអ្នកចូលរួមចំនួន១០នាក់ (ស្ត្រី៥ និង បុរស៥) ដែលមិនធ្លាប់ឆ្លងកាត់ការលែងលះក៏ត្រូវបានសម្ភាសផងដែរ ដើម្បីបង្ហាញពីការយល់ឃើញ និងផ្តត់គំនិតសាធារណៈរបស់អ្នកដែលមិនធ្លាប់ជួបប្រទះការលែងលះឱ្យកាន់តែទូលំទូលាយលើប្រធានបទនេះ។

ជាចុងក្រោយ អ្នកចូលរួមចំនួន ៥ នាក់មកពីអង្គការសង្គមស៊ីវិលដែលធ្វើការលើ បញ្ហាយេនឌ័រ និង/ឬ ការលែងលះ (ពួកគេម្នាក់ៗបានឆ្លងកាត់ការលែងលះ) ត្រូវបានសម្ភាសដើម្បីផ្តល់ការយល់ដឹងអំពីសិទ្ធិស្ត្រី និងការលែងលះនៅកម្ពុជា ក៏ដូចជាចែករំលែកបទពិសោធន៍ និងការរៀនសូត្ររបស់ពួកគេ។

# កូដនីយកម្ម និងការវិភាគ

គ្រប់សមាជិកក្រុមស្រាវជ្រាវសកម្មបានចូលរួមយ៉ាងសកម្ម នៅគ្រប់ដំណាក់កាលទាំងអស់នៃការសិក្សាស្រាវជ្រាវ មិនមែន ត្រឹមតែជា 'អ្នកប្រមូលទិន្នន័យ' ដែលបានទទួល កម្រងសំណួរដើម្បីចុះទៅសម្ភាសន៍ ហើយបញ្ជូនកម្រង សំណួរត្រឡប់វិញតែប៉ុណ្ណោះទេ។ ដើម្បីធ្វើកូដនីយកម្ម ទិន្នន័យបែបគុណវិស័យ វគ្គបណ្តុះបណ្តាល និងអនុវត្តផ្ទាល់ ស្តីពីការវិភាគមូលបទទិន្នន័យ ផ្អែកតាមគោលការណ៍ណែនាំ របស់ Braun & Clarke (២០១៣) ត្រូវបានរៀបចំឡើង នៅភ្នំពេញ [៧]។ ក្រុមអ្នកស្រាវជ្រាវសកម្មបានវិភាគជាបន្ត បន្ទាប់ និងកំណត់កូដទិន្នន័យសម្ភាសន៍ដោយផ្ទាល់។

សម្រង់សម្តីដកស្រង់ចេញពីការសម្ភាសន៍ជាមួយអ្នកចូលរួម ត្រូវបានដាក់ស្លាកសម្គាល់ដោយអក្សរ 'D' ឬ 'ND' ដើម្បី សម្គាល់អ្នកចូលរួមដែលឆ្លងកាត់ការលែងលះ ឬ មិនធ្លាប់ឆ្លង កាត់ការលែងលះ។ ឧទាហរណ៍ DW5 សម្គាល់អ្នកចូលរួម ស្ត្រីឆ្លងកាត់ការលែងលះ ខណៈដែល NDM12 សម្គាល់អ្នក ចូលរួមបុរសដែលមិនធ្លាប់ឆ្លងកាត់ការលែងលះ (បទ សម្ភាសន៍ ទី១២)។ ស្ត្រីទាំងប្រាំនាក់ដែលធ្វើការងារនៅតាម អង្គការសង្គមស៊ីវិលត្រូវបានដាក់ស្លាកពី CW1 ដល់ CW5។ ជាអកុសល្យ ដោយខុសពីគម្រោងសិក្សាស្រាវជ្រាវ របស់Klahaanកន្លងមក ការសិក្សាស្រាវជ្រាវនេះមិនបាន ដាក់បញ្ចូលទស្សនៈជាក់លាក់របស់ក្រុមLGBTQI+ នោះទេ។ មូលហេតុនោះគឺដោយសារតែភាពជាក់លាក់នៃប្រធានបទ ស្រាវជ្រាវ និងស្ថានភាពរឹតត្បិតកំណត់លើការរៀបការ និង ការលែងលះនៅក្នុងបរិបទកម្ពុជា ពោលគឺការលែងលះអាចធ្វើ ឡើងបានតែរវាងស្វាមីភរិយាដែលមានភេទផ្ទុយគ្នាប៉ុណ្ណោះ។

# ការស្ទង់មតិអនឡាញ

បន្ថែមពីលើការសម្ភាសន៍ ការស្ទង់មតិអនឡាញមួយបានធ្វើឡើង ដើម្បីផ្តល់នូវការយល់ដឹងតាមបែបបរិមាណវិស័យ បន្ថែមទៀត ដែលការស្ទង់មតិនេះមានអ្នកឆ្លើយតបចំនួន១00នាក់។ ទិន្នន័យ ត្រូវបានវិភាគដោយប្រើប្រាស់កម្មវិធី Excel ហើយរបកគំហើញ ត្រូវបានដាក់បញ្ចូលនៅតាមផ្នែកនីមួយៗនៃរបាយការណ៍នេះ។ ដោយសារតែការសិក្សានេះគឺជា ការសិក្សាបែបគុណវិស័យដែល ព្យាយាមឈ្វេងយល់ពីជម្រៅ និងភាពសម្បូរបែបនៃបទពិសោធន៍ ជាជាង ការស្ទង់មតិបរិមាណទ្រង់ទ្រាយធំ ដូច្នេះវាមិនអាច និង គ្មានគោលបំណងប្រើប្រាស់តំណាងឲ្យប្រជាជនកម្ពុជាទូទាំងផ្ទៃ ប្រទេសនោះទេ។










# ៣

# ឧបសគ្គ និងកត្តាជំរុញ នៃការលេងលះ

# ៣. ឧបសគ្គ និងកត្តាជំរុញនៃការលែងលះ

នេះគឺជាផ្នែកទីមួយនៃមូលបទទាំងបីនៅក្នុងសិក្សាស្រាវជ្រាវនេះ ដែលឈ្វេងយល់ពីបទពិសោធន៍ និងផ្នត់គំនិតអ្នកចូលរួមចំពោះការលែងលះនៅកម្ពុជា។ ផ្នែកនេះត្រួតពិនិត្យមើលជាពិសេសទៅលើបរិបទដែលស្ត្រីស្វែងរកការលែងលះ និងថាតើជម្រើសរបស់ពួកគេត្រូវបានគ្រួសារ សហគមន៍ ក៏ដូចជាសង្គមទាំងមូលវិនិច្ឆ័យដោយរបៀបណា។

ពាក់កណ្តាលនៃផ្នែកដំបូង (ផ្នែកទី ៣.១) ពិនិត្យមើល 'កត្តាជំរុញ' នៃការលែងលះ (មូលហេតុទូទៅដែលស្ត្រីស្វែងរក ការលែងលះ) ខណៈពេលដែលពាក់កណ្តាលនៃផ្នែកចុងក្រោយ (ផ្នែក៣.២) ឈ្វេងយល់អំពី 'ឧបសគ្គ' សង្គមជាក់លាក់ ផ្អែកលើយេនឌ័រ (ហេតុផលទូទៅដែលស្ត្រីមិនអាច ឬបង្វែងមិនឱ្យមានការលែងលះ) ។

## ៣.១ មូលហេតុដែលស្ត្រីស្វែងរកការលែងលះ (‘កត្តាជំរុញ’)

*“គាត់ប្រើហិង្សាលើខ្ញុំ... ខ្ញុំមិនដែលចង់លែងលះគាត់ទេ ព្រោះខ្ញុំស្រលាញ់គាត់ ប៉ុន្តែវាបានឈានដល់ចំណុចដែលខ្ញុំមិនអាចទ្រាំទ្របានទៀតទេ។”*

(DW6)។

កត្តាជំរុញទូទៅដំបូងដែលលេចចេញពីបទសម្ភាសន៍និងទិន្នន័យស្ទង់មតិអនឡាញគឺជា អំពើហិង្សាបង្កឡើងដោយដៃគូស្និទ្ធស្នាល (IPV)។ អង្គការ WHO បានកំណត់និយមន័យ IPV ថាជា "អាកប្បកិរិយាក្នុងទំនាក់ទំនងស្និទ្ធស្នាលដែលបណ្តាលឱ្យមានគ្រោះថ្នាក់ដល់រាងកាយ ផ្លូវភេទ ឬផ្លូវចិត្ត រួមទាំងអំពើបំពានលើរាងកាយ ការបង្ខិតបង្ខំផ្លូវភេទ ការរំលោភបំពានផ្លូវចិត្ត និងអាកប្បកិរិយាត្រួតត្រាដោយបង្ខំ" [៨] ។

ក្នុងចំណោមអ្នកឆ្លើយតបការស្ទង់មតិអនឡាញភាគច្រើនក៏បានរាយការណ៍ដែរថា IPV គឺជាបុព្វហេតុចម្បងដែលនាំឲ្យស្ត្រីក្នុងប្រទេសកម្ពុជាឲ្យស្វែងរកការលែងលះ ខណៈដែលគេយល់ថា មូលហេតុចម្បងដែលបុរសស្វែងរកការលែងលះនោះ គឺ "ការអស់មនោសញ្ចេតនាស្នេហា"។ អ្នកឆ្លើយសំណួរក៏បានបង្ហាញដែរថាជាទូទៅអំពើហិង្សាកើតឡើងចំពោះស្ត្រីជាងបុរស៖ ខណៈពេលដែលពីរភាគបី (៦៦%) នៃអ្នកឆ្លើយសំណួរបានរាយការណ៍ថា IPV គឺជាហេតុផលសំខាន់ដែលជម្រុញឲ្យស្ត្រីជ្រើសរើសលែងលះ ផ្ទុយទៅវិញមានតែ ១៦% ប៉ុណ្ណោះដែលបានរាយការណ៍ថា IPV គឺជាហេតុផលសំខាន់ដែលបុរសជ្រើសរើសលែងលះ។



សម្រាប់អ្នកឆ្លើយសម្ភាសន៍ស្ត្រីជាច្រើន IPV ត្រូវបានគេរាយការណ៍ថា បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការសម្រេចចិត្តស្វែងរកការលែងលះ។ ការសម្ភាសន៍បែបគុណវិស័យបានផ្តល់សក្ខីកម្មជាច្រើនដែលពិពណ៌នាអំពី ការរំលោភបំពានលើរាងកាយ ដោយអតីតស្វាមី ជាពិសេសនៅពេលការប្រច័ណ្ឌ ឬមិនពេញចិត្តកើតឡើង៖ "យើងធ្លាប់ឈ្លោះគ្នាគ្រប់ពេល ហើយគាត់ប្រច័ណ្ឌខ្ញុំជាមួយសាច់ញាតិខ្ញុំ។ គាត់មិនចង់ឱ្យពួកគេមកលេងខ្ញុំទេ។ គាត់តែងតែធ្វើបាបរូបខ្ញុំគ្រប់ពេលដែលគាត់ស្រវឹង"(DW2)។ ប្រភេទ និងភាពធ្ងន់ធ្ងរនៃអំពើហិង្សាផ្លូវកាយដែលត្រូវបានពិពណ៌នាដោយអ្នកចូលរួមមានភាពខុសប្លែកគ្នាច្រើន រាប់ចាប់តាំងពីការវាយដំដែលធ្វើឱ្យពួកគេមានស្នាមជាំនៅលើដៃ(DW2) រហូតដល់ "ការរុញច្រាន និងទះកំផ្លៀង"(DW13) រហូតឈានដល់អំពើហិង្សាធ្ងន់ធ្ងរ ដូចជាការដាល់ចំកណ្តាលមុខ និងការបណ្តាលឲ្យបាត់បង់ទារកដែលមិនទាន់កើតដោយសារតែការរលូតកូន (DW6)។

គួរកត់សម្គាល់ថា អ្នកឆ្លើយសំណួរភាគច្រើនដែលបានពិពណ៌នាថា IPV គឺជាកត្តាជំរុញចម្បងដែលនាំឲ្យពួកគេស្វែងរកការលែងលះនោះ ក៏បានរាយការណ៍ដែរថាពួកគេមិនបានចាត់វិធានការភ្លាមៗដើម្បីធ្វើការលែងលះនោះទេ នៅពេលដែលអំពើហិង្សាកើតឡើងលើកទីមួយ ឬលើកទីពីរនោះ។ ជាទូទៅពួកគេស្វែងរកការលែងលះបន្ទាប់ពីអំពើហិង្សាបានកើតឡើងដដែលៗក្នុងរយៈពេលយូរអង្វែង។ នៅក្នុងករណីនេះ ស្ថានភាពនៃអំពើហិង្សាមាននិន្នាការកើនឡើង ញឹកញាប់ និងមានសភាពធ្ងន់ធ្ងររហូតដល់អ្នកឆ្លើយតប "មិនអាចទ្រាំទ្រនឹងការឈឺចាប់បានទៀតទេ" (DW2)។ ដូចអ្នកឆ្លើយតបម្នាក់បាននិយាយថា "[អំពើហិង្សា] បង្កការឈឺចាប់ខ្លាំងរហូតដល់ខ្ញុំមិនអាចបន្តរស់នៅជាមួយគាត់ទៀតបាន" (DW5)។

ករណីធ្ងន់ធ្ងរនៃការរំលោភបំពានផ្លូវចិត្តក៏មានបង្ហាញនៅទូទាំងទិន្នន័យសម្ភាសន៍ផងដែរ ជាក់ស្តែងមានអ្នកឆ្លើយតបម្នាក់បានរាយការណ៍ថា អតីតប្តីរបស់នាងបានបោកចានបោកឆ្នាំងពេញផ្ទះ និងជាញឹកញយបានប្រើប្រាស់កាំភ្លើងដើម្បីសម្លុតកំហែងនាង(DW22)។ អ្នករស់រានមានជីវិតពីការរំលោភបំពានផ្លូវចិត្តបានស៊ូទ្រាំនឹងការប៉ះទង្គិចផ្លូវចិត្ត ឬរបួសស្នាមផ្លូវចិត្ត និងផ្លូវអារម្មណ៍ ដោយសារតែដៃគូរបស់ពួកគេ ជាញឹកញយបានប៉ុនប៉ងត្រួតត្រា បំភិតបំភ័យ និងបំបែកពួកគេពីគ្រួសារ មិត្តភ័ក្តិ តាមរយៈពាក្យសម្តី និងមធ្យោបាយទំនាក់ទំនងផ្សេងៗទៀត [៩]។

ជាការពិតណាស់ អាកប្បកិរិយាត្រួតត្រាគឺជាមូលបទលេចធ្លោមួយនៅក្នុងទិន្នន័យដោយមានអ្នកឆ្លើយតបម្នាក់បានរាយការណ៍ថា៖ "អតីតស្វាមីរបស់ខ្ញុំមិនអនុញ្ញាតឱ្យខ្ញុំសម្រេចចិត្តលើអ្វីនោះទេ។ គាត់ថែមទាំងដាក់បម្រាមគោចរ... [ហើយ] ខ្ញុំមិនអាចទិញសម្លៀកបំពាក់ថ្មី ឬគ្រឿងអលង្ការបានទេ" (DW6)។ ស្រដៀងគ្នានេះដែរ ម្នាក់ទៀតបានផ្តល់សក្ខីកម្មថា សិទ្ធិទទួលបានឱកាសការងាររបស់នាងត្រូវបានរឹតត្បិតដោយសារតែអាកប្បកិរិយាត្រួតត្រានេះ៖ "គាត់គ្រាន់តែចង់ត្រួតត្រា ហើយចង់ឈ្នះ...ខ្ញុំមិនធ្វើការនៅខាងក្រៅផ្ទះទេព្រោះគាត់តែងតែប្រច័ណ្ឌ"(DW2)។ ក្នុងករណីដ៏គួរឲ្យព្រួយបារម្ភមួយ អ្នកចូលរួមម្នាក់បានរំឭកថា នាងរស់នៅក្រោមការគំរាមសម្លាប់ដោយអតីតប្តីរបស់នាង៖ "[គាត់] ធ្លាប់គំរាមខ្ញុំដោយប្រើ កាំភ្លើង ប៉ុន្តែខ្ញុំបានព្យាយាមតឡូល់ និងសួរគាត់ថា តើអ្នកណាមើលថែកូនយើង ប្រសិនបើខ្ញុំស្លាប់បាត់នោះ? (DW16)។

អំពើហិង្សាផ្លូវភេទ រួមទាំងអំពើរំលោភផ្លូវភេទក្នុងចំណងអាពាហ៍ពិពាហ៍ក៏រំលេចឡើងនៅក្នុងទិន្នន័យផ្តល់ឲ្យដោយអ្នកឆ្លើយតបសំណួរជាច្រើនថាជាកត្តាជំរុញឱ្យមានការលែងលះ។ ករណីខាងក្រោមនេះផ្តល់ដោយបុគ្គលិកអង្គការសង្គមស៊ីវិលដែលឆ្លងកាត់ការលែងលះ ដែលចូលរួមផ្តល់បទសម្ភាសន៍នៅក្នុងការសិក្សាស្រាវជ្រាវនេះ បង្ហាញពីរបៀបដែលទម្រង់នៃអំពើហិង្សាជាច្រើនដែលត្រួតស៊ីគ្នា – ផ្លូវកាយ ផ្លូវភេទ និងសេដ្ឋកិច្ច – បានរឹតត្បិតជម្រើសនិងស្វ័យភាពរបស់ស្ត្រីនៅក្នុងអាពាហ៍ពិពាហ៍ដែលនៅទីបំផុតបានជំរុញឱ្យនាងឈានដល់ការលែងលះ៖

> *“ក្នុងករណីខ្ញុំមានអំពើហិង្សាផ្លូវភេទរួមទាំងការរំលោភផ្លូវភេទ។ លើសពីនេះទៀតអំពើហិង្សាខាងសេដ្ឋកិច្ច ក៏កើតឡើងផងដែរ។ ខ្ញុំត្រូវទទួលខុសត្រូវរាល់ការចំណាយក្នុងគ្រួសារ ជាពិសេសថ្លៃរស់នៅរបស់កូនៗ...*
>
> *គាត់បានចាប់រំលោភខ្ញុំដោយបង្ខំក្នុងយប់មង្គលការរបស់យើង... ជាអកុសលខ្ញុំមានផ្ទៃពោះពីសកម្មភាពរំលោភនោះ ដូច្នេះខ្ញុំគ្មានជម្រើសអ្វីក្រៅពីនៅជាមួយគាត់... ខ្ញុំកាន់តែភ័យខ្លាចហើយជឿថាខ្ញុំគ្មានផ្លូវចេញ... ខ្ញុំទ្រាំរស់នៅក្នុងស្ថានភាពនោះយ៉ាងយូរ រហូតដល់ខ្ញុំធ្លាក់ខ្លួនឈឺហើយចង់នៅឆ្ងាយពីគាត់” (CW4)។*

ក៏ដូចជាIPVដែរ អ្នកឆ្លើយសំណួរមួយចំនួនក៏បានពណ៌នាអំពី អំពើហិង្សាលើកូន របស់ពួកគេ (ឬការភ័យខ្លាចថានឹងមានអំពើហិង្សាកើតឡើងចំពោះពួកគេនាពេលអនាគត) ថាបានរួមចំណែកដល់ការសម្រេចចិត្តរបស់ពួកគេក្នុងការស្វែងរកការលែងលះ។ សម្រាប់អ្នកផ្សេងទៀត ការសម្រេចចិត្តលែងលះរបស់ពួកគេគឺមិនបណ្តាលមកពីអំពើហិង្សាផ្លូវកាយទេ ប៉ុន្តែបណ្តាលមកពីការឈ្លោះប្រកែកគ្នា ការមិនចុះសម្រុងគ្នា ឬមិនសប្បាយចិត្តនៅក្នុងទំនាក់ទំនង។ ឧទាហរណ៍ ការបដិសេធមិនធ្វើការងារថែទាំគ្មានប្រាក់កម្រៃ និងកិច្ចការផ្ទះ (DW13) អារម្មណ៍មិនសប្បាយចិត្តជាមួយគ្នាជាទូទៅ និងកង្វះនូវទំនាក់ទំនង(DW7) អារម្មណ៍ដែលមិនទទួលបានការគោរព និងផ្តល់តម្លៃ ហើយនឹងការឈ្លោះ ប្រកែកតតឈប់ឈ "សូម្បីតែរឿងតូចតាច" (DW11)។

ការបែងចែក–រវាងអាកប្បកិរិយាមិនសមហេតុផល/ខុសទំនង និងការបំពាន– អាចមានភាពស្រពេចស្រពិលនៅក្នុងកាលៈទេសៈខ្លះ។ ឧទាហរណ៍ វាអាចពិបាកក្នុងការបែងចែករវាងអាកប្បកិរិយាដែលអាចបង្កើតជា 'អំពើរំលោភបំពានផ្លូវអារម្មណ៍' (ដូចមានកំណត់ក្នុងច្បាប់កម្ពុជាថាជាអាកប្បកិរិយាដែលរួមមាន "ការបៀតបៀនដែលបណ្តាលឱ្យប៉ះពាល់ដល់ផ្លូវចិត្ត/អារម្មណ៍ សតិបញ្ញា ឬដល់រូបកាយមនុស្សក្នុងគ្រួសារ...[ដែលលើសពី] សីលធម៌និងព្រំដែននៃច្បាប់” [១០]) និង អាកប្បកិរិយាដែលមិនសប្បាយចិត្ត និងតូចចិត្ត ប៉ុន្តែជួនកាលមិនមែន បទល្មើសនោះទេ។

ស្រដៀងគ្នានេះដែរ ការសម្រង់សម្ដីសំភាសន៍ជាច្រើនដែលពិភាក្សាអំពីអតីតដៃគូដែលធ្លាប់ត្រួតត្រា ឬជួនកាលមិនអាចទុកចិត្តបានលើរឿងលុយកាក់ ឬទ្រព្យសម្បត្តិ។ យ៉ាងណាមិញ អាកប្បកិរិយាទាំងអស់នេះមិនត្រូវបានពិពណ៌នាយ៉ាងច្បាស់ថាជា អំពើរំលោភបំពានផ្នែកហិរញ្ញវត្ថុ នោះទេ (យុទ្ធសាស្ត្រដែលមនុស្សម្នាក់អនុវត្តការត្រួតត្រា តាមរយៈការរឹតបន្តឹងលទ្ធភាពរបស់ប្ដី ឬប្រពន្ធរបស់ពួកគេក្នុងការទទួលបានហិរញ្ញវត្ថុក្នុងគ្រួសារ)៖

*“[ការលែងលះគឺ] ដោយសារតែគាត់មិនបានជួយដោះស្រាយបញ្ហារបស់យើង។ ឧទាហរណ៍ខ្ញុំត្រូវសងបំណុលតែម្នាក់ឯង ហើយគាត់មិនព្រមចែករំលែកបន្ទុកនោះទេ។ ដូច្នេះ ហេតុអ្វីបានជាខ្ញុំនៅតែនៅជាមួយគាត់? បើខ្ញុំត្រូវដោះស្រាយបញ្ហាតែម្នាក់ឯង រស់នៅតែម្នាក់ឯងគឺល្អជាងមែនទេ? នោះជាអ្វីដែលខ្ញុំបានគិត»។ (DW19) ។*

សម្ពាធផ្នែកហិរញ្ញវត្ថុត្រូវបានរាយការណ៍ដោយអ្នកឆ្លើយសំណួរជាច្រើនថាបានកើនឡើងដោយសារកត្តាមួយចំនួនដូចជា ការញៀនល្បែងរបស់ប្ដី ការញៀនស្រា និងទំនោរក្នុងការ"ចំណាយប្រាក់ច្រើនជាងអ្វីដែលគាត់រកបាន" (DM3)។ អ្នកខ្លះ ក៏បានរាយការណ៍ថាមានកត្តាខាងក្រៅមួយចំនួនទៀតដូចជា បំណុល ការបាត់បង់ដីធ្លី និងជំងឺរាតត្បាត COVID-19 បានបង្កើនសម្ពាធហិរញ្ញវត្ថុដែលបណ្ដាលឱ្យពួកគេលែងលះគ្នា(DW21)។ សម្រាប់អ្នកចូលរួមម្នាក់ កង្វះទំនួលខុសត្រូវផ្នែកហិរញ្ញវត្ថុរបស់អតីតស្វាមីរបស់នាង បានក្លាយទៅជាបញ្ហាដែលមិនអាចទ្រាំទ្រទៀតបាននៅពេលដែលនាងមានបញ្ហាសុខភាព៖

*"បុរសមិនគាំទ្រប្រពន្ធរបស់ពួកគេផ្នែកហិរញ្ញវត្ថុទេ។ ពួកគេមិនដឹងពីរបៀបថែរក្សាប្រពន្ធ ឬកូនរបស់ពួកគេទេ ហើយភាគច្រើនគ្រាន់តែផ្ដោតលើខ្លួនឯងប៉ុណ្ណោះ។ ស្ត្រី [រងទុក្ខ] នៅពេលដែលប្ដីរបស់ពួកគេមិនគាំទ្រពួកគេ ផ្នែកហិរញ្ញវត្ថុ និងចំណាយប្រាក់លើគ្រឿងស្រវឹង និងល្បែង។ ក្នុងករណីរបស់ខ្ញុំ... ដោយសារគាត់មិនខ្វល់ពីការទទួលខុសត្រូវរបស់គាត់ គាត់មិនដែលខ្វល់ខ្វាយពីខ្ញុំពេលខ្ញុំឈឺ — មិនដែលផ្ញើប្រាក់ មិនដែលលើកទឹកចិត្តខ្ញុំ ហើយមិនដែលធ្វើឱ្យខ្ញុំមានអារម្មណ៍កក់ក្ដៅ» (DW9) ។*

សម្រង់សម្ដីខាងលើអាចចាត់ទុកថា ការយល់ឃើញពីកង្វះការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុរបស់ស្វាមីត្រូវបានផ្សារភ្ជាប់ទៅនឹងការខកខានក្នុងការបំពេញតួនាទីយេនឌ័រដែលរំពឹងទុកជាទូទៅនៅក្នុងអាពាហ៍ពិពាហ៍ភេទផ្ទុយគ្នា។ អ្នកឆ្លើយតបម្នាក់ បានពោលយ៉ាងច្បាស់ថា៖ “ស្ត្រីសម្រេចចិត្តលែងលះនៅពេលដែល...គ្រួសារគ្មានបង្គោលគ្រួសារដែលអាចទុកចិត្តបាន។ វាប្រហែលជាដោយសារប្ដីញ៉ាំគ្រឿងស្រវឹងច្រើនពេក ហើយមិនបានធ្វើការ ឬប្រើអំពើហិង្សា» (DW15)។

ជាការពិតណាស់ អ្នកចូលរួមទាំងបុរស និងស្ត្រីបានកំណត់ថា ការខកខានក្នុងការបំពេញតួនាទីយេនឌ័រដែលរំពឹងទុកជាហេតុផលមួយដែលនាំឲ្យមានការលែងលះ។ តួនាទីយេនឌ័រ និងការរំពឹងទុកនៅក្នុងទំនាក់ទំនងភេទផ្ទុយគ្នាបានកំណត់សម្រាប់ទាំងស្វាមី និងភរិយា ហើយការខកខានមិនបំពេញតាមការរំពឹងទុកនោះនាំឱ្យមានការមិនពេញចិត្ត និងជួនកាលនាំឲ្យឈានដល់ការលែងលះសម្រាប់ស្ត្រី។ ទស្សនៈដែលថា ស្វាមីគួររកចំណូលបានគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់គ្រួសារនោះ អ្នកឆ្លើយសំណួរមួយចំនួនក៏ហាក់បង្ហាញផ្នត់គំនិត និងការរំពឹងទុកជាក់លាក់ចំពោះការបង្ហាញភាពជាបុរសរបស់ស្វាមីផងដែរ។ ឧទាហរណ៍ អ្នកឆ្លើយសំណួរម្នាក់បានណែនាំថា "ស្ត្រីចង់បានដៃគូដែលក្លាហាន សុភាពបុរស ឬមានមុខមាត់ក្នុងសង្គម" (DW16)។

ម្យ៉ាងវិញទៀត ស្ត្រីត្រូវបានគេរំពឹងទុកថានឹងប្រព្រឹត្តខ្លួនជា 'ស្ត្រីមេផ្ទះត្រឹមត្រូវ' ដើម្បីបំពេញតម្រូវការរបស់ស្វាមី។ ទាំងបុរស និងស្ត្រីដែលឆ្លើយតបសំណួរបានបង្ហាញការយល់ស្របថា ស្ត្រីដែលតែងតែចេញក្រៅផ្ទះមិនថាដើម្បីលំហែកាយ ឬបំពេញការងារនោះទេជាទូទៅ អាចជាមូលហេតុមួយដែលនាំឲ្យមានការលែងលះ។ ជាការពិតណាស់ បុរសដែលឆ្លើយសំណួរម្នាក់បានពន្យល់ពីការលែងលះរបស់អ្នកជិតខាគាត់ថា ដោយសារតែ "ប្រពន្ធមិនដែលនៅផ្ទះទេ នាងតែងតែចេញទៅក្រៅ"(DM2)។ ស្រដៀងគ្នានេះដែរ ស្ត្រីដែលឆ្លងកាត់ការលែងលះម្នាក់បានចែករំលែកថា«ខ្ញុំជឿថាការលែងលះរបស់ យើងបានកើតឡើងដោយសារតែការងាររបស់ខ្ញុំតម្រូវឱ្យខ្ញុំធ្វើដំណើរច្រើន»(CW3)។ ដូច្នេះហើយអាជីពការងារស្ត្រីអាចជាបញ្ហានៅក្នុងអាពាហ៍ពិពាហ៍ដោយសារតែវាចម្រូងចម្រាស់ជាមួយនឹងការរំពឹងទុកខាងយេនឌ័រ ជាពិសេសនៅពេលដែលវាបង្កើតជាចំណោទសួរទាក់ទងនឹងតួនាទីចម្បងរបស់បុរសក្នុងការផ្គត់ផ្គង់គ្រួសារ។

ការរំពឹងទុកដែលមិនអាចសម្រេចបានមួយចំនួនមិនភ្ជាប់ទៅនឹងយេនឌ័រនោះទេ ប៉ុន្តែជាការរំពឹងទុកជាទូទៅនៅក្នុងទំនាក់ទំនង។ ចំណុចទាំងនេះទាក់ទងទៅនឹងរបៀបរបបរស់នៅប្រចាំថ្ងៃ ទស្សនៈមតិ និងទំនួលខុសត្រូវផ្សេងទៀត។ ឧទាហរណ៍ អ្នកចូលរួមស្ត្រីម្នាក់បានសំដៅទៅលើ "ការយល់ច្រលំ និងការមិនអាចបំពេញតាមរំពឹងទុកជាច្រើនរបស់ភាគីទាំងសងខាង"(CW5) ហើយបុរសម្នាក់បានលើកឡើងអំពី "របៀបរស់នៅនិងទស្សនៈខុសៗគ្នា" (NDM3) ថាជាមូលហេតុដែលនាំឲ្យមានការលែងលះ។

កត្តាជំរុញជាទូទៅចុងក្រោយដែលរំលេចឡើងនៅក្នុងទិន្នន័យដែលនាំឲ្យស្ត្រីធ្វើការលែងលះនោះគឺ អំពើផិតក្បត់។ ៨១% នៃអ្នកឆ្លើយតបការស្ទង់មតិអនឡាញបង្ហាញថា "ការបោកប្រាស់ និងផិតក្បត់" គឺជាមូលហេតុដែលទំនងជាស្ត្រីជ្រើសរើសការលែងលះ ខណៈមានតែ៦៨%ប៉ុណ្ណោះដែលបានជ្រើសរើសចម្លើយដូចគ្នាទាក់ទងនឹងបុរស។ ដូចទៅនឹងការពិភាក្សា អំពី IPV នៅក្នុងផ្នែកខាងលើនេះ ទិន្នន័យសំភាសន៍ហាក់ដូចជាបង្ហាញពីនិន្នាការមួយដែលថាជាធម្មតាស្ត្រីស្វែងរកការលែងលះប្តីរបស់ពួកគេបន្ទាប់ពីអំពើបោកប្រាស់កើតឡើងជាច្រើនដង ឬអំពើផិតក្បត់អូសបន្លាយរយៈពេលវែង ជាជាងបន្ទាប់ពីការផិតក្បត់កើតឡើងតែម្តង ឬពីរដង៖

> *“គាត់បានកុហកខ្ញុំតាំងពីថ្ងៃយើងរៀបការដំបូង។ ខ្ញុំតែងតែតាមមើលគាត់រហូត តាមរហូតដល់ថ្នាក់ហត់នឿយខ្លាំង ហត់រហូតលែងខ្វល់ទៀត។ ដូច្នេះខ្ញុំបានត្រឹមតែសុំគាត់ឲ្យលាក់រឿងរ៉ាវក្បត់ផិតរបស់គាត់ពីខ្ញុំ។ អ្វីដែលខ្ញុំចង់បាន គឺគ្រួសារមួយដែលកូនរបស់ខ្ញុំមានឪពុកម្តាយទាំងពីរនៅជាមួយគ្នា។ ប៉ុន្តែថ្ងៃមួយ សកម្មភាពរបស់គាត់គឺ ហួសហេតុពេក។ គាត់បាននាំនាងទៅដេកនៅផ្ទះដែលយើងបានសង់ជាមួយគ្នា។ នៅទីបំផុត ខ្ញុំបានសម្រេចចិត្តលក់ផ្ទះនោះ ហើយលែងលះគ្នា” (DW20)។*

ការអត់ធ្មត់ខ្ពស់ចំពោះភាពមិនស្មោះត្រង់នេះ មួយផ្នែកអាចដោយសារផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចនិងសង្គមធ្ងន់ធ្ងរចំពោះស្ត្រីដែលបណ្ដាលមកពីការលែងលះ។ ចំណុចនេះនឹងត្រូវបានពិភាក្សានៅក្នុងផ្នែកបន្ទាប់នៃរបាយការណ៍នេះ។ បុរសឆ្លងកាត់ការលែងលះម្នាក់បានឆ្លើយតបនឹងគំនិតនេះដោយពោលថា "ក្នុងករណីខ្លះប្រពន្ធក៏ដឹងអំពីរឿងក្បត់ចិត្តនោះដែរ ប៉ុន្តែនាង ជ្រើសរើសទ្រាំទ្រនឹងការឈឺចាប់ និងសង្គ្រោះជីវិតអាពាហ៍ពិពាហ៍ ព្រោះនាងមិនអាចរស់នៅតែម្នាក់ឯងបាន" (DM3)។ ផ្ទុយទៅវិញ ការឆ្លើយតបអំពីអំពើផិតក្បត់របស់ស្ត្រីហាក់មានភាពដាច់ដោយឡែកជាង៖ «ថ្មីៗនេះ បុរសម្នាក់ដែលបានតាមទាន់ប្រពន្ធខ្លួនកំពុងប្រព្រឹត្តអំពើក្បត់ជាមួយបុរសម្នាក់ទៀតនៅផ្ទះសំណាក់។ បុរសជាប្តីសម្រេចចិត្តប្តឹងលែងលះ» (NDW2)។

អ្នកឆ្លើយតបជាបុគ្គលិកអង្គការសង្គមស៊ីវិលម្នាក់បានផ្តល់ជាមតិថា បុរសទំនងជាមិនសូវស្វែងរកការលែងលះទេ ដោយសារពួកគេមានសេរីភាព និងស្វ័យភាពច្រើននៅក្នុងអាពាហ៍ពិពាហ៍ បើប្រៀបធៀបទៅនឹងស្ត្រី។ ឧទាហរណ៍ ខណៈដែលស្ត្រីត្រូវរឹតត្បិត និងប្រព្រឹត្តខ្លួនក្នុងទម្រង់ជាក់លាក់មួយបន្ទាប់ពីរៀបការ (ឧទាហរណ៍ស្ត្រីដែលផ្តល់សម្ភាសន៍ក្នុងការសិក្សានេះបានរាយការណ៍ថាបានបោះបង់ការងារ ឬកំហិតជីវិតសង្គមរបស់ពួកគេ) បុរសបានរក្សាសេរីភាពប្រហាក់ប្រហែលទៅនឹងស្ថានភាពរបស់ពួកគេមុនពេលរៀបការរួមទាំងសេរីភាពនៅក្នុងទំនាក់ទំនងស្នេហា៖

*“តាមគំនិតរបស់ខ្ញុំ បុរសភាគច្រើនមិនចូលចិត្តលែងលះគ្នាទេ ព្រោះថា បើទោះបីជាពួកគេរៀបការហើយក៏ដោយក៏ពួកគេនៅតែអាចធ្វើរឿងជាច្រើនបាន រួមទាំងការបោកប្រាស់ផិតក្បត់ប្រពន្ធរបស់ពួកគេផងដែរ” (CW3) ។*





## ៣.២ មូលហេតុដែលស្រ្តីមិនអាចធ្វើការលែងលះ (‘ឧបសគ្គ’)

*«ដោយសារតែជំនឿសន្មតអំពីយេនឌ័រនៅកម្ពុជា ស្រ្តីដែលលែងលះត្រូវបានគេវិនិច្ឆ័យយ៉ាងខ្លាំង បើប្រៀបធៀប ទៅនឹងបុរស។ សង្គមតែងតែយល់ឃើញថា ស្រ្តីនោះប្រាកដជាបានធ្វើអ្វីខុសឆ្គងមិនខាន» (CW1)។*

ផ្នែកនេះផ្លាស់ប្តូរពីកត្តាជំរុញទូទៅដែលរាយការណ៍ថាបានជំរុញឲ្យស្រ្តីស្វែងរកការលែងលះ ទៅពិនិត្យមើលឧបសគ្គទូទៅ ផ្នែកសង្គមនិងវប្បធម៌ ដែលស្រ្តីជួបប្រទះ និងបានរារាំង និងបន្ទុចបង្អាក់ពួកគេមិនឲ្យចាកចេញពីអាពាហ៍ពិពាហ៍។

ឧបសគ្គទីមួយក្នុងចំណោមទាំងអស់នេះ ត្រូវបានគេរាយការណ៍ថាជាសម្ពាធដែលត្រូវរក្សាចំណងអាពាហ៍ពិពាហ៍ដើម្បីរក្សាភាពសុខដុមរមនា និងរក្សាមុខមាត់។ ប្រភពនៃសម្ពាធនេះអាចមានច្រើនខុសៗគ្នា ប៉ុន្តែជាទូទៅគឺជាសមាជិកគ្រួសារ ជាពិសេសគឺឪពុកម្តាយ បងប្អូន និងអ្នកជិតខាង និងអាជ្ញាធរមូលដ្ឋាន៖

> *“...នៅតែមានការវិនិច្ឆ័យពីអ្នកដ៏ទៃ – នៅពេលដែលគាត់បានឮពីការលែងលះ ឪពុករបស់ខ្ញុំមានអារម្មណ៍មិនល្អចំពោះចៅប្រុសរបស់គាត់ ដូច្នេះគាត់បានព្យាយាមផ្សះផ្សាពួកយើង។ គាត់មិនសប្បាយចិត្តទេពេលខ្ញុំរើចេញ ហើយតែងតែបញ្ចុះបញ្ចូលខ្ញុំឱ្យត្រឡប់ទៅរស់នៅជាមួយប្តីខ្ញុំវិញ... ប្អូនៗរបស់ខ្ញុំក៏ដាក់សម្ពាធលើខ្ញុំដែរ ដោយប្រាប់ខ្ញុំថាខ្ញុំត្រូវតែផ្លាស់ទៅផ្ទះវិញ ហើយរស់នៅជាមួយគ្នាម្តងទៀត » (DW16) ។*

ជាការពិតណាស់ អ្នកឆ្លើយសំណួរស្ត្រីជាច្រើនបានរាយការណ៍ថា ពួកគេមានអារម្មណ៍ថាខ្វះការគាំទ្រ ឬរងការវិនិច្ឆ័យពីគ្រួសាររបស់ពួកគេទាក់ទងនឹងការសម្រេចចិត្តលែងលះ។ ពួកគេបានពិពណ៌នាអំពីទស្សនៈទូទៅដែលថាការដែលមានសមាជិកគ្រួសារលែងលះគ្នានឹងនាំមកនូវភាពអាម៉ាស់ដល់គ្រួសារទាំងមូល។ ហេតុដូច្នេះហើយ សាច់ញាតិតែងតែលើកទឹកចិត្តយ៉ាងខ្លាំងឱ្យជ្រើសរើសការការផ្សះផ្សាជាមួយស្វាមីជាជាងការចែកផ្លូវ និងការលែងលះ៖

> *“នៅពេលដែលខ្ញុំព្យាយាមលែងលះប្ដីរបស់ខ្ញុំជាលើកដំបូង គ្រួសាររបស់ខ្ញុំបានបញ្ចុះបញ្ចូលខ្ញុំឱ្យផ្លាស់ប្ដូរការសម្រេចចិត្តរបស់ខ្ញុំ និងឲ្យផ្សះផ្សាជាមួយអតីតប្ដីរបស់ខ្ញុំ។ គ្មានការពិភាក្សាអំពីសុខភាពផ្លូវចិត្ត និងសុខុមាលភាពរបស់ខ្ញុំទេ។ ខ្ញុំមានជំងឺធ្លាក់ទឹកចិត្តអស់រយៈពេលជាច្រើនឆ្នាំក្នុងអាពាហ៍ពិពាហ៍របស់ខ្ញុំ” (CW2) ។*

សម្ពាធពីសមាជិកគ្រួសារក្នុងការបន្តអាពាហ៍ពិពាហ៍កើតឡើងដោយសារតែ ភាពអាម៉ាស់ និងការមាក់ងាយ នៅក្នុងសង្គមចំពោះស្ត្រីដែលលែងលះគ្នាក្នុងប្រទេសកម្ពុជា។ នៅក្នុងការស្ទង់មតិអនឡាញមានអ្នកចូលរួមជាច្រើនលើសលប់រហូតដល់ ៨៧% បានរាយការណ៍ពីជំនឿថា ស្ត្រីត្រូវបានរងផលប៉ះពាល់ដោយភាពអាម៉ាស់ ឬការមាក់ងាយនៅក្នុងសង្គមច្រើនជាងបុរសបន្ទាប់ពីការលែងលះ ធៀបនឹង១% ដែលយល់ថាបុរសទទួលរងភាពអាម៉ាស់ ឬការមាក់ងាយច្រើនជាង៖

**តើអ្នកគិតថា នរណាដែលទទួលរងផលប៉ះពាល់ដោយ ការមាក់ងាយ ការវិនិច្ឆ័យ ឬភាពអាម៉ាសពីសង្គម ច្រើនជាងក្រោយពេលលែងលះ?**



អ្នកចូលរួមសម្ភាសន៍ជាច្រើនបានរាយការណ៍ថា ពួកគេប្រឈមនឹងឧបសគ្គសង្គមជាច្រើនដែលរារាំងពួកគេមិនឱ្យឈានដល់ការលែងលះ ពោលគឺពួកគេបានជ្រើសរើសបន្តរស់នៅក្នុងចំណងអាពាហ៍ពិពាហ៍ដែលគ្មានសុភមង្គលយ៉ាងហោចណាស់មួយរយៈពេល។ អ្នកចូលរួមស្ត្រីដែលឆ្លងកាត់ការលែងលះម្នាក់បានពន្យល់ថា "ស្ត្រីនៅតែត្រូវបាន វិនិច្ឆ័យច្រើនជាងបុរស ពីព្រោះ... សង្គមនៅតែស្តីបន្ទោសស្ត្រីដែលលែងលះគ្នា។ ពួកគេត្រូវបានគេនិយាយអាក្រក់អំពី និងមើលងាយ” (DW12) ។

ការឆ្លើយតបរបស់អ្នកចូលរួមជាច្រើនក៏បានបង្ហាញដែរថា ជំនឿសន្មតសង្គមទាក់ទងស្ត្រីដែលលែងលះថា ជាស្ត្រីមានអត្តចរិកមិនល្អ ឬខ្វះសីលធម៌។ ដូចដែលអ្នកចូលរួមជាបុរសលែងលះម្នាក់បាននិយាយថា៖ «ខ្ញុំគិតថាអតីតភរិយារបស់ខ្ញុំទទួលបានការវិនិច្ឆ័យច្រើនជាងខ្ញុំ។ ខ្ញុំគិតថាមនុស្សម្នាបាននិយាយដើមគាត់ដូចជាថា 'ព្រោះអ្នកមានអត្តចរិកមិនល្អ ទើបបានប្ដីលែងលះអ្នក”(DM3)។ ជំនឿសន្មតមួយទៀតនោះគឺថាស្ត្រីដែលឆ្លងកាត់ការលែងលះជាស្ត្រីដ៏គួរឲ្យអាណិត៖ “សង្គមនៅតែចាត់ទុកការលែងលះជារឿងអវិជ្ជមានជាពិសេសចំពោះស្ត្រី។ ទោះជាស្ត្រីជោគជ័យឬឯករាជ្យខាងសេដ្ឋកិច្ចក៏ដោយ ប្រសិនបើនាងលែងលះគ្នានោះមនុស្សក្នុងសង្គមអាណិតនាង ហើយមើលទៅនាងជាស្ត្រីអភ័ព្វ” (CW3) ។

បទដ្ឋានសម្រាប់បុរសដែលលែងលះគ្នាត្រូវបានគេរាយការណ៍ថាមានភាពខុសប្លែកគ្នាពីស្ត្រី ដែលនាំឲ្យមើលឃើញដោយ ងាយស្រួលនូវការអនុវត្តន៍ស្តង់ដារទ្វេគុណ៖“សង្គមស្តាប់តែភាគីម្ខាងនៃរឿងប៉ុណ្ណោះ។ ហាក់បីដូចជាសម្ដីបុរសមានទម្ងន់ ជាងសម្ដីស្ត្រី។ មនុស្សម្នាមិនខ្វល់ថាបុរសមានប្រពន្ធផ្សេងក្រោយការលែងលះនោះទេ ប៉ុន្តែប្រសិនបើស្ត្រីរៀបការម្តង ទៀតនោះ ពួកគេនឹងចោទប្រកាន់នាងថាមានទំនាក់ទំនងស្នេហាផិតក្បត់ ហើយសន្មតថានោះជាហេតុផលដែលនាង លែងលះគ្នា” (NDW1) ។

សញ្ញាណវប្បធម៌ ដែលចាត់ទុកស្ត្រីជាអ្នកការពារ និងអ្នករក្សាភាពសុខដុមរមនាក្នុងគ្រួសារក៏ត្រូវបានគេរាយការណ៍ថា បានដើរតួជាឧបសគ្គរារាំងស្ត្រីមិនឱ្យស្វែងរកការលែងលះដែលពួកគេចង់ធ្វើ៖ «មនុស្សម្នារំពឹងថាស្ត្រីនឹងស៊ូទ្រាំ និងការពារភាពសុខដុមរមនាក្នុងគ្រួសារ។ នេះដោយសារតែ មនុស្សមានទំនោរប្រើប្រាស់ចក្ខុយេនឌ័របែបប្រពៃណីពិនិត្យមើលបញ្ហាទាំងអស់នេះ” (CW3)។

ដូចបានកត់សម្គាល់ដោយ Brickell(២០១៤) និងដោយ WPM នៅក្នុងការស្រាវជ្រាវលើប្រធានបទ(២០២០) មានការគូសបញ្ជាក់ពីការផ្សាភ្ជាប់ភាពសុខដុមរមនា និងការផ្សះផ្សានៅក្នុងវប្បធម៌កម្ពុជា [១១,១២]។ Brickell ពន្យល់ថា "ស្ថានភាពសង្គមរបស់ស្ត្រីនៅតែត្រូវវាស់វែងផ្អែកលើភាពសុខដុមរមនានៃទំនាក់ទំនងអាពាហ៍ពិពាហ៍ និងភាពជាម្តាយ" [១៣]។ ចំណុចនេះក៏ត្រូវបានបង្ហាញនៅក្នុងគោលបំណងនៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារឆ្នាំ២០០៧ ដែលចែងថា “...ដើម្បីបង្កើតយន្តការច្បាប់ក្នុងការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការពារជនរងគ្រោះ និងរក្សាភាពសុខដុមរមនាក្នុងគ្រួសារស្របតាមទំនៀមទម្លាប់ និងប្រពៃណីល្អរបស់ប្រទេសជាតិ”។ អាស្រ័យហេតុនេះ ទំនោរវប្បធម៌តែងតែផ្តោតលើ “ការសម្រុះសម្រួលនិងផ្សះផ្សាជម្លោះនៅក្នុងអាពាហ៍ពិពាហ៍ ជាជាងការជួយសម្រួលដល់សិទ្ធិស្មើគ្នាក្នុងការរំលាយអាពាហ៍ពិពាហ៍”[១៤]។ ជាការពិត បទដ្ឋានវប្បធម៌ និងប្រពៃណីត្រូវបានបង្ហាញជាទូទៅនៅក្នុងទិន្នន័យថា ជាកត្តាដ៏មានឥទ្ធិពលដែលបន្ទុចបង្អាក់ទឹកចិត្តស្ត្រីមិនឲ្យស្វែងរកការលែងលះ៖

*“ស្ត្រីដែលឆ្លងកាត់ការលែងលះ ត្រូវបានសង្គមកាត់ទោសធ្ងន់ជាងបុរស។ វាអាចដោយសារបទដ្ឋានប្រពៃណី និងផ្នត់គំនិតដែលមានទស្សនៈថា ស្ត្រីមិនអាចធ្វើអ្វីផ្សេងក្រៅពីកិច្ចការផ្ទះបានឡើយ» (NDM3)។*

ឧបសគ្គមួយទៀតដែលអ្នកចូលរួមយល់ឃើញថា ជាឧបសគ្គរារាំងស្ត្រីមិនឱ្យទទួលបានការលែងលះ គឺការ ខ្វះការអប់រំ និងខ្វះព័ត៌មានអំពីនីតិវិធីលែងលះ។ អ្នកចូលរួមម្នាក់បានពណ៌នាថា៖

*“ខ្ញុំមិនបានទទួលព័ត៌មានច្រើនទាក់ទងនឹងនីតិវិធីលែងលះនោះទេ។ ព័ត៌មានអំពីដំណើរការផ្លូវច្បាប់ នៅមាន កម្រិតខ្លាំង ហើយមនុស្សជាច្រើនមិនបានដឹងនោះទេ។ ព័ត៌មានមិនមានជាសាធារណៈសម្រាប់មនុស្សម្នាចូល ប្រើប្រាស់ទេ ដូច្នេះមនុស្សមិនសូវដឹងច្រើនទេ»។*

នៅពេលអ្នកឆ្លើយសំណួរដដែលត្រូវបានសួរដោយអ្នកសម្ភាសន៍ថា ប្រសិនបើលទ្ធភាពទទួលបានព័ត៌មាននៅមានកម្រិត ធ្វើឱ្យមានការពិបាកដាក់ពាក្យសុំលែងលះនោះ គាត់បានឆ្លើយតបដូចខាងក្រោម៖

*“បាទ ខ្ញុំគិតថាវាពិបាកណាស់។ អ្នកដែលចង់លែងលះមិនដឹងថាត្រូវធ្វើយ៉ាងណា ឬចាប់ផ្តើមពីណាទេ។ ឧទាហរណ៍ ប្រសិនបើស្ត្រីជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ ហើយនាងត្រូវការជំនួយ នាងមិនដឹងថាត្រូវស្វែងរកជំនួយពីទីណានោះទេ។*

*បើនាងទៅរកឪពុកម្តាយប្រហែលជាពិបាក ដោយសារតែផ្តត់គំនិតវិនិច្ឆ័យរបស់ពួកគេ។ ខ្ញុំជឿថា ប្រសិនបើយើងមានប្រព័ន្ធមួយដែលជួយឱ្យពលរដ្ឋរាយការណ៍ពីបញ្ហារបស់ពួកគេ ឬទទួលបានព័ត៌មាន វានឹងមានប្រយោជន៍ជាង” (NDM4) ។*



ឧបសគ្គបន្ថែមមួយទៀតដែលត្រូវបានលើកឡើងជាទូទៅនៅក្នុងទិន្នន័យថាបានរារាំងស្ត្រីដែលកំពុងស្វែងរកការលែងលះគឺ ការយល់ឃើញពីផលប៉ះពាល់សង្គម និងផ្លូវចិត្តលើកូន។ អ្នកចូលរួមសម្ភាសន៍ម្នាក់បានរៀបរាប់អំពីរឿងនេះ៖

*“ហេតុផលមួយទៀតដែលមនុស្សចាស់មិនចង់ឱ្យកូនៗលែងលះគ្នានោះ គឺដោយសារតែពួកគេបារម្ភថាចៅៗរបស់ពួកគេនឹងត្រូវមាក់ងាយដោយមិត្តភក្តិរបស់ពួកគេនៅសាលា ដោយសារមិនមានម្តាយ ឬឪពុក [ព្រោះ] ពួកគេគ្មានគ្រួសារពេញលេញមួយ” (DW3 )។*

អ្នកចូលរួមជាស្ត្រីជាច្រើនបាននិយាយថា ពួកគេបានពន្យារការលែងលះដោយសារតែបំណងប្រាថ្នាមិនចង់ឲ្យកូនរបស់ពួកគេ "គ្មានឪពុក"។ អ្នកចូលរួមម្នាក់បានរាយការណ៍ថា បានស៊ូទ្រាំនឹងអាពាហ៍ពិពាហ៍ដែលគ្មានសុភមង្គលមួយរយៈ ដោយសារតែនាងត្រូវបានគេប្រាប់ម្តងហើយម្តងទៀតថា អនាគតរបស់កូនៗអាចប្រឈមនឹងបញ្ហា៖ “នៅពេលដែលខ្ញុំកំពុងពិចារណាអំពីការលែងលះ មនុស្សម្នាតែងតែប្រាប់ខ្ញុំឱ្យគិតអំពីអនាគតកូនរបស់ខ្ញុំ។ ពួកគេបានផ្តល់យោបល់ថា កូនរបស់ខ្ញុំប្រហែលជាគ្មានអនាគតល្អទេ បើគ្មានវត្តមានរបស់អតីតស្វាមីខ្ញុំ» (CW1) ។

អ្វីដែលគួរឱ្យចាប់អារម្មណ៍ផងដែរនោះគឺថា បទដ្ឋានទាំងនេះរីករាលដាលខ្លាំងដែលសូម្បីតែអ្នកចូលរួមស្ត្រីមួយចំនួនដែលធ្លាប់ឆ្លងកាត់ការលែងលះផ្ទាល់ក៏នៅតែបង្ហាញជំហរគាំទ្រយ៉ាងម៉ឺងម៉ាត់ថា៖

*«ខ្ញុំគិតថាការលែងលះមិនមែនជារឿងល្អសម្រាប់សង្គមទេ ពីព្រោះកូនត្រូវរស់នៅដោយគ្មានឪពុក ឬម្តាយ។ ហើយវាក៏មិនល្អសម្រាប់សង្គមដែរ ប្រសិនបើស្ត្រីត្រូវមានប្តីលើសពីមួយ” (DW9)។*

ឃ្លាទីពីរនៅក្នុងសម្រង់សម្តីខាងលើបានលើកឡើងពីឧបសគ្គរារាំងចុងក្រោយដែលរំលេចឡើងជាទូទៅនៅក្នុងទិន្នន័យនោះគឺ វប្បធម៌ព្រហ្មចារី។ អ្នកចូលរួមបានកំណត់ការយល់ឃើញពីវប្បធម៌មួយចំនួន ទាក់ទងនឹងភាពបរិសុទ្ធ ឧទាហរណ៍ ការចាត់ទុកស្ត្រីម្នាក់ជា "ក្រណាត់ស" ហើយគួរតែមានដៃគូរួមភេទតែមួយប៉ុណ្ណោះពេញមួយជីវិតរបស់នាង។ លើសពីនេះ អ្នកចូលរួមមួយចំនួនបានកត់សម្គាល់ពីបម្រាមសង្គមជុំវិញការលែងលះ និងការរំពឹងទុកថាស្ត្រីនឹងនៅតែរក្សាចំណងអាពាហ៍ពិពាហ៍ដោយមិនគិតពីថាតើអាពាហ៍ពិពាហ៍មានការលំបាកយ៉ាងណានោះ៖

*«វាចាក់ឫសគល់នៅក្នុងតម្លៃវប្បធម៌របស់យើង។ សង្គមរបស់យើងរំពឹងថាស្ត្រីនឹងមានដៃគូផ្លូវភេទតែមួយ... វាត្រូវបានទទួលយកដោយគ្មានសំណួរអ្វីទាំងអស់ថា ហេតុអ្វីស្ត្រីមិនគួរចេញទៅក្រៅផ្ទះច្រើន ឬមានដៃគូច្រើនទេ” (CW1) ។*

អ្នកចូលរួមមួយចំនួនបានចែករំលែកថា ស្ត្រីត្រូវប្រឈមជាមួយជំនឿសង្គមដែលថា ការមានដៃគូរួមភេទច្រើននឹងធ្វើឲ្យស្ត្រីក្លាយទៅ ស្រីល្ហេចល្ហាច និងធ្វើឱ្យនាងបាត់បង់នូវភាពទាក់ទាញសម្រាប់ឱកាសអាពាហ៍ពិពាហ៍លើកក្រោយ។ ជំនឿសន្មតនេះបានក្លាយទៅជាឧបសគ្គសង្គមក្នុងការស្វែងរកការលែងលះ។ អ្នកចូលរួមម្នាក់បានគូសបញ្ជាក់ពីសម្ពាធសង្គមក្នុងការរក្សាអាពាហ៍ពិពាហ៍ដោយឈរលើមូលដ្ឋានថា នៅពេលដែលស្ត្រីម្នាក់បាត់បង់ព្រហ្មចារីយ៍ជាមួយប្តីរបស់នាងនោះ ការរៀបការម្តងទៀតនឹងជួបការពិបាកនៅពេលដែល "តម្លៃ" របស់នាងបានថយចុះនៅក្នុងក្រសែភ្នែករបស់បុរសផ្សេងទៀតដែលចង់បានដៃគូមានភាពបរិសុទ្ធ។ ហេតុដូច្នេះ ស្ត្រីដែលរៀបការជាច្រើននាក់សុខចិត្តបន្តរក្សាចំណងអាពាហ៍ពិពាហ៍ដែលពួកគេមិនសប្បាយចិត្តជាមួយ។

*“បុរសមានឱកាសច្រើនជាងស្ត្រី និងអាចស្វែងរកដៃគូថ្មីបានយ៉ាងងាយស្រួលជាងស្ត្រី ហើយខ្ញុំគិតថាព្រោះតែរឿងព្រហ្មចារីនេះឯង។ ក្រោយការលែងលះស្ត្រីអាចនឹងបាត់បង់សម្រស់ក៏ដូចជាបាត់បង់ព្រហ្មចារី ដូច្នេះហើយ មនុស្សជាច្រើនមិនចង់បានស្ត្រីដែលឆ្លងកាត់ការលែងលះនោះទេ។ ខ្ញុំគិតថាស្ត្រីនឹងប្រឈមជាមួយបញ្ហាជាច្រើនបន្ទាប់ពីការលែងលះ” (NDW3) ។*

# ៣. ឧបសគ្គ និងកត្តាជំរុញ សេចក្តីសន្និដ្ឋាន

ផ្នែកនេះបានស្វែងយល់ពីបរិបទដែលស្ត្រីស្វែងរកការលែងលះនៅក្នុងប្រទេសកម្ពុជា និងរបៀបដែលការសម្រេចចិត្តលើជម្រើសរបស់ពួកគេត្រូវបានវិនិច្ឆ័យដោយគ្រួសារ សហគមន៍ និងសង្គមទូលំទូលាយ។ ពាក់កណ្តាលនៃផ្នែកទីមួយបាន ត្រួតពិនិត្យមើលកត្តាជំរុញទូទៅដែលនាំឲ្យមានការលែងលះ និងបានរកឃើញថាកត្តាជំរុញទាំងនោះរួមមាន អំពើហិង្សាបង្កឡើងដោយដៃគូស្និទ្ធិស្នាល (ជាញឹកញយគឺជាបណ្តុំត្រួតស៊ីគ្នានៃអំពើហិង្សាផ្លូវកាយ ផ្លូវចិត្តផ្លូវភេទ និង/ឬ អំពើហិង្សា ផ្នែកសេដ្ឋកិច្ច) ការញៀនគ្រឿងស្រវឹងនិងល្បែង ការមិនអាចបំពេញតាមការរំពឹងទុកផ្នែកតួនាទីយេនឌ័រការឈ្លោះប្រកែក និងអំពើផិតក្បត់។

ពាក់កណ្តាលទៀតនៃផ្នែកនេះ ឈ្វេងយល់អំពីឧបសគ្គសង្គមជាក់លាក់អំពីយេនឌ័រដែលជាទូទៅបានរារាំង ឬបង្វែងស្ត្រីពីការទទួលបានការលែងលះ។ ឧបសគ្គទាំងនេះរួមមាន ភាពអាម៉ាស់ក្នុងគ្រួសារនិងសង្គមឬការវិនិច្ឆ័យ។ កង្វះការអប់រំ និងព័ត៌មានអំពីនីតិវិធីលែងលះ ការយល់ឃើញអំពីផលប៉ះពាល់អវិជ្ជមាននៃការលែងលះលើកូន និងវត្តមានវប្បធម៌ព្រហ្មចារីដែលចាក់ឬសគល់យ៉ាងជ្រៅ និងបានមាក់ងាយស្ត្រីដែលមានដៃគូរួមភេទលើសពីមួយក្នុងមួយជីវិត។



# ៤

# ដំណើរការលែងលះ៖
# នីតិវិធីបិតាធិបតេយ្យ

# ៤. ដំណើរការលែងលះ៖ នីតិវិធីបិតាធិបតេយ្យ

នៅក្នុងមូលបទនេះ របាយការណ៍នឹងបង្វែរទៅពិនិត្យមើលបទពិសោធន៍របស់ស្ត្រីពាក់ព័ន្ធនឹងដំណើរការនីតិវិធីលែងលះ បែបបិតាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា ដោយពិនិត្យមើលទាំងនីតិវិធីលែងលះសម្រាប់ អាពាហ៍ពិពាហ៍ស្របច្បាប់ និង អាពាហ៍ពិពាហ៍ប្រពៃណី។ បទពិសោធន៍ទាំងនេះរួមមាន សម្ពាធក្នុងការផ្សះផ្សាជាមួយប្តីឬប្រពន្ធ ជាជាងការបន្តការចែកផ្លូវគ្នា ឬការលែងលះ និងឧបសគ្គផ្សេងទៀតដូចជា ការចំណាយថវិកា និងឧបសគ្គផ្នែករដ្ឋបាល។

ផ្នែកនេះក៏ឈ្វេងយល់អំពីការយល់ឃើញរបស់ស្ត្រីផ្ទាល់ទាក់ទងនឹងគុណភាពជីវិត និងសុខុមាលភាពរបស់ពួកគេក្រោយការលែងលះទាំងផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមាន។



## ៤.១ ការលែងលះ ‘អាពាហ៍ពិពាហ៍ផ្លូវការ’

សម្រាប់ដៃគូដែលមានអាពាហ៍ពិពាហ៍ផ្លូវការ ឧទាហរណ៍ ដៃគូដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍ នីតិវិធីលែងលះមានចែងនៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។ នីតិវិធីនេះត្រូវបានសង្ខេបដោយអ្នកជំនាញផ្នែកច្បាប់ Dorine van der Keur (២០១៤) [១៥] ដូចខាងក្រោម៖

*អាពាហ៍ពិពាហ៍ស្របច្បាប់ ជាអាពាហ៍ពិពាហ៍ដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវនៅការិយាល័យអត្រានុកូលដ្ឋាន ហើយអាចបញ្ចប់បានដោយដីកាលែងលះស្របច្បាប់ដែលចេញដោយតុលាការតែប៉ុណ្ណោះ។ សំណើសុំលែងលះអាចដាក់ដោយផ្ទាល់ទៅតុលាការ ឬដាក់ជូនក្រុមប្រឹក្សាឃុំសង្កាត់សង្កាត់។ ប្រសិនបើសំណើត្រូវបានដាក់ទៅក្រុមប្រឹក្សាឃុំសង្កាត់ ក្រុមប្រឹក្សាមានពេល១៥ថ្ងៃដើម្បីព្យាយាមផ្សះផ្សា។ ប្រសិនបើការព្យាយាមរបស់ក្រុមប្រឹក្សាឃុំសង្កាត់មិនបានជោគជ័យ ក្រុមប្រឹក្សាឃុំសង្កាត់គួរបញ្ជូនពាក្យសុំលែងលះទៅតុលាការ។*

*ក្រោយពីទទួលបានសំណើសុំលែងលះតុលាការនឹងកោះហៅភាគីទាំងសងខាងមកតុលាការ។ ចៅក្រមភាគច្រើននឹងបញ្ចុះបញ្ចូលដើមបណ្តឹងឲ្យដកសំណើលែងលះ។ ប្រសិនបើដើមបណ្តឹងនៅតែបន្តចង់លែងលះតុលាការ អាចចាត់ចែងជាបណ្តោះអាសន្ន... នៅដំណាក់កាលនេះ ជាធម្មតា តុលាការនឹងព្យាយាមសម្របសម្រួលចំនួនបីដងដើម្បីមើលថា តើប្តីប្រពន្ធអាចផ្សះផ្សាគ្នាបានដែរឬទេ។ ប្រសិនបើដើមបណ្តឹងនៅតែបន្តចង់លែងលះ តុលាការនឹងធ្វើការសម្រេចចិត្ត លើការលែងលះដែលបានស្នើសុំការបែងចែកទ្រព្យសម្បត្តិរួម ប្រាក់ឧបត្ថម្ភរបស់ដៃគូ អំណាចមេបារសិទ្ធិទៅលេងកូន និងកាតព្វកិច្ចអាហារកិច្ច។*

ជាងពាក់កណ្ដាលនៃអ្នកឆ្លើយសំណួរស្ត្រីដែលឆ្លងកាត់ការលែងលះដែលត្រូវបានចូលរួមក្នុងការសិក្សានេះ បានធ្វើការលែងលះតាមនីតិវិធីផ្លូវការ (១៤ ក្នុងចំណោម ២៧ នៃអ្នកចូលរួម)។ ក្នុងចំណោមអ្នកឆ្លើយសំណួរជាបុរសដែលឆ្លងកាត់ការលែងលះដែលផ្តល់សម្ភាសនៅក្នុងការសិក្សានេះ ម្នាក់បានឆ្លងកាត់នីតិវិធីលែងលះផ្លូវការ (ធៀបនឹងពីរនាក់ដែលឆ្លងកាត់នីតិវិធីមិនផ្លូវការ)។ ក្នុងករណីខ្លះអ្នកឆ្លើយសំណួរបានបញ្ជាក់ពីភាពចាំបាច់នៃទំនាក់ទំនង ជាមួយប្រព័ន្ធតុលាការផ្លូវការ ដើម្បីសម្រេចលើការបែងចែកអំណាចមេបារ ឬការបែងចែកទ្រព្យសម្បត្តិ ទោះបីជាពួកគេគ្មានសំបុត្រអាពាហ៍ពិពាហ៍ស្របច្បាប់ក៏ដោយ។

បញ្ហាដែលលើកឡើងដោយអ្នកឆ្លើយសំណួរដែលបានឆ្លងកាត់ការលែងលះបែបផ្លូវការរួមមានបន្ទុក ផ្នែកហិរញ្ញវត្ថុ ដែលត្រូវចំណាយនៅក្នុងប្រព័ន្ធតុលាការ និង/ឬ សោហ៊ុយជួលមេធាវីឯកជន។ ការប្រើប្រាស់ពេលវែងនៅក្នុងដំណើរការនីតិវិធី និងកង្វះការគាំទ្រ និងការលើកទឹកចិត្តដល់ស្ត្រីក្នុងការទាមទារផលប្រយោជន៍ផ្ទាល់ខ្លួនរបស់ពួកគេ។

អ្នកចូលរួមសម្ភាសន៍ដែលប្រើប្រាស់សេវាគាំទ្រផ្នែកច្បាប់ឯកជនបានស្ម័គ្រចិត្តផ្តល់ព័ត៌មានអំពីថវិកាចំណាយសរុបថា មានចាប់ពី ៥០០ដុល្លារ ដល់ ៣០០០ដុល្លារ។ ហើយក៏មានការចំណាយបន្ថែមផ្សេងទៀតដែលពិពណ៌នាដោយអ្នកឆ្លើយសំណួរមួយចំនួន៖

*"ការដាក់ពាក្យបណ្តឹងសុំលែងលះនៅតុលាការ ប្រហែលជាមិនចំណាយច្រើនទេ។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើនរណាម្នាក់ចង់ពន្លឿនសំណុំរឿងរបស់ពួកគេ គេអាចនឹងត្រូវចំណាយប្រហែល ២០០០-៣០០០ ដុល្លារ វាអាស្រ័យលើភាពស្មុគស្មាញនៃសំណុំរឿង។ ហើយនេះនៅត្រូវគិតបញ្ចូលថ្លៃមេធាវីក្រៅទៀត... មិត្តខ្ញុំនាក់បានចំណាយប្រហែល $១៣០០០ នៅក្នុងដំណើរការលែងលះរបស់នាង" (CW4)។*

អ្នកឆ្លើយសំណួរជាបុរសម្នាក់បានលើកឡើងអំពីសារៈសំខាន់នៃការចំណាយថវិកានៅក្នុងនីតិវិធីលែងលះ៖

*«នៅកម្ពុជា បើយើងមានលុយ វាពិតជាងាយស្រួល។ តែបើយើងអត់មានលុយក៏មិនស្រួលដែរ។ ជាធម្មតា ប្រសិនបើយើងស្គាល់មេធាវីនោះ តម្លៃនៃការលែងលះនឹងស្ថិតនៅក្រោម$១០០០។ ប៉ុន្តែប្រសិនបើយើងមិនស្គាល់នរណាម្នាក់សោះ យើងអាចចំណាយប្រហែល $១.៥k ទៅ $២k អាស្រ័យលើថា តើយើងចង់ឱ្យការលែងលះនេះលឿនប៉ុណ្ណា" (DM3)។*

ចុងក្រោយ អ្នកឆ្លើយសំណួរជាស្ត្រីម្នាក់បានឆ្លុះបញ្ចាំងអំពីតថភាពពិតថា ប្រសិនបើនាងគ្មានថវិកាច្រើនសន្ធឹកសន្ធាប់ ដើម្បីចំណាយនៅក្នុងដំណើរការនេះទេ នាងនឹងមិនអាចទទួលបានការលែងលះនោះទេ៖

> ***"ដំណើរការលែងលះគឺពិតជាមានការលំបាកនៅក្នុងប្រទេសកម្ពុជា... ខ្ញុំអាចទទួលបានការលែងលះស្របច្បាប់ ព្រោះខ្ញុំមានលុយសម្រាប់ចំណាយនៅក្នុងដំណើរការនេះ។ ប្រសិនបើខ្ញុំគ្មានលុយទេ ខ្ញុំនឹងមិនអាចលែងលះបានទេ។ ហើយអតីតប្តីរបស់ខ្ញុំនឹងនៅតែមាននៅក្នុងជីវិតរបស់ខ្ញុំ» (DW20) ។***

ដូចគ្នានឹងបន្ទុកផ្នែកហិរញ្ញវត្ថុដ៏ធ្ងន់ធ្ងរដែលបានកើតឡើង អ្នកឆ្លើយតបដែលឆ្លងកាត់ការលែងលះជាច្រើនបានឆ្លុះបញ្ចាំងអំពីការអូសបន្លាយពេលវេលានៅក្នុងដំណើរការលែងលះផ្លូវការ។ អ្នកចូលរួមម្នាក់បានពោលថា ទោះបីជា "យើងទាំងពីរ បានយល់ព្រមលែងលះគ្នា ហើយគ្មានជម្លោះទាក់ទងនឹងការបែងចែកទ្រព្យសម្បត្តិក៏ដោយ ក៏នីតិវិធីដែលដំណើរការនៅក្នុងប្រព័ន្ធតុលាការផ្លូវការបានចំណាយពេលជិតមួយឆ្នាំពេញ"(CW5)។ អ្នកឆ្លើយតបមួយផ្សេងទៀត(CW4) បានផ្តល់ព័ត៌មានថាដំណើរការលែងលះអាចចំណាយពេលរហូតដល់៣ឆ្នាំដើម្បីបញ្ចប់។

មូលបទមួយទៀតដែលលេចឡើងដដែលៗនៅក្នុងទិន្នន័យផ្តល់ដោយអ្នកឆ្លើយតបសម្ភាសន៍ដែលឆ្លងកាត់នីតិវិធីលែងលះផ្លូវការនោះគឺ ឧបសគ្គផ្នែករដ្ឋបាល។ ខណៈពេលដែលមនុស្សមួយចំនួន ជាពិសេសអ្នកដែលមានទំនាក់ទំនងគ្រួសារជា មួយអ្នកជំនាញផ្នែកច្បាប់ ឬមន្ត្រីតុលាការហាក់អាចឆ្លងកាត់ដំណើរការនីតិវិធីនេះបានដោយរលូន និងយ៉ាងឆាប់រហ័ស អ្នកចូលរួមជាច្រើន បានពោលថាបានជួបបញ្ហាប្រឈមដែលបង្កឡើងដោយដំណើរការការិយាធិបតេយ្យ និងបានចំណាយពេលច្រើន៖

*“សម្រាប់ខ្ញុំ ដំណើរការលែងលះគឺពិបាកណាស់។ ពេលខ្ញុំទៅតុលាការសុំពាក្យសុំលែងលះដោយខ្លួនឯងដោយគ្មានជំនួយគាំទ្រពីមេធាវី មន្ត្រីតុលាការបានឲ្យខ្ញុំរង់ចាំហើយរង់ចាំទៀត។ បន្ទាប់មកខ្ញុំត្រូវជួលមេធាវីមកជួយក្នុងការដាក់ពាក្យរបស់ខ្ញុំ។ ទោះបីជាមានការជួយជ្រោមជ្រែងពីមេធាវីក៏ដោយ ខ្ញុំត្រូវទៅតុលាការជាច្រើនដងសម្រាប់វគ្គផ្សះផ្សា ហើយចន្លោះពេលរងចាំរវាងវគ្គផ្សះផ្សានីមួយៗគឺគ្មានការកំណត់ជាក់លាក់នោះទេ - ជាទូទៅ គឺវាអាស្រ័យលើធនធាន និងបណ្តាញរបស់យើងនៅក្នុងប្រព័ន្ធតុលាការ។ វាត្រូវចំណាយប្រាក់ និងពេលវេលា ច្រើន» (CW2) ។*

អ្នកឆ្លើយសំណួម្នាក់មានអារម្មណ៍ថាឧបសគ្គផ្នែករដ្ឋបាលដែលស្ត្រីប្រឈមមុខនៅពេលស្វែងរកការលែងលះហាក់ដូចជា មិនបានបណ្តាលមកពីភាពស្មុគស្មាញនៅក្នុងនីតិវិធីច្បាប់នោះទេ ប៉ុន្តែឧបសគ្គនោះគឺបង្កឡើងដោយអ្នកដែលធ្វើការនៅក្នុងប្រព័ន្ធច្បាប់ទៅវិញទេ៖

*«នីតិវិធីច្បាប់មិនស្មុគស្មាញទេ ប៉ុន្តែមន្ត្រីតុលាការបានបង្កការលំបាកនិងធ្វើឲ្យចំណាយពេលច្រើន។ មិនចាំបាច់ធ្វើវិសោធនកម្មនីតិវិធីលែងលះនោះទេ ប៉ុន្តែត្រូវមានការកែលម្អទាក់ទងនឹងការអនុវត្តច្បាប់។ វាក៏សំខាន់ផងដែរក្នុងការលុបបំបាត់អំពើពុករលួយនៅក្នុងប្រព័ន្ធតុលាការ” (CW5) ។*

បទពិសោធន៍ចុងក្រោយដែលអ្នកឆ្លើយតបចែករំលែកទាក់ទងនឹងការលែងលះជាផ្លូវការ នោះគឺការដាក់សម្ពាធពីមន្ត្រីឱ្យ ផ្សះផ្សា ជាមួយប្តីឬប្រពន្ធរបស់ពួកគេជំនួសឱ្យការបន្តការលែងលះ។ អ្នកឆ្លើយសំណួរម្នាក់បានរំលឹកថា “ក្នុងអំឡុងពេលនោះ មន្ត្រីតុលាការបានព្យាយាមផ្សះផ្សាពួកយើង... តុលាការបានសុំឱ្យខ្ញុំប្រានចោលឯកសារលែងលះ ប៉ុន្តែខ្ញុំមិនបានដកចេញទេ”(DW16)។ អ្នកឆ្លើយតបម្នាក់ទៀតបានរំលឹកឡើងវិញថា ការសម្រេចបន្តដំណើរកការលែងលះគឺជាការសម្រេចចិត្តដ៏ត្រឹមត្រូវក្នុងរឿងក្តីរបស់នាង ទោះបីជាឆ្លងកាត់នីតិវិធីតុលាការផ្សះផ្សាដ៏ស្មុគស្មាញក៏ដោយ៖

*“ការលែងលះសម្រាប់អ្នកដែលមានសំបុត្រអាពាហ៍ពិពាហ៍គឺពិបាក ប៉ុន្តែប្រសិនបើគេពិតជាចង់លែងលះពួកគេ នៅតែអាចធ្វើបាន។ សូម្បីតែបន្ទាប់ពីតុលាការសុំឱ្យប្តីប្រពន្ធផ្សះផ្សា... ក្នុងករណីរបស់ខ្ញុំដោយសាររឿងអាក្រក់ ជាច្រើនបានកើតឡើងខ្ញុំបារម្ភថាប្រសិនបើខ្ញុំបន្តរស់នៅក្នុងអាពាហ៍ពិពាហ៍តើអ្នកណាអាចដឹងថានឹងកើតឡើងនាពេលអនាគត” (DW6) ។*

## អនុសាសន៍សម្រាប់កែលម្អនីតិវិធីលែងលះផ្លូវការ៖

ដូចជាការឆ្លុះបញ្ចាំងពីបទពិសោធន៍ និងបញ្ហាប្រឈមដែលជួបប្រទះក្នុងដំណើរការលែងលះតាមផ្លូវច្បាប់ អ្នកចូលរួមជាច្រើនបានផ្តល់អនុសាសន៍សម្រាប់ការកែលម្អដំណើរការនេះ។ អនុសាសន៍ទាំងនេះ រួមមានការពន្លឿនដំណើរការនីតិវិធី និងការកាត់បន្ថយឬលុបបំបាត់នីតិវិធីផ្សះផ្សាដែលកំណត់ដោយតុលាការនាពេលបច្ចុប្បន្ន៖ «ប្រសិនបើដំណើរការលែងលះអាចលឿនជាងនេះវាពិតជាល្អណាស់។ ខ្ញុំមិនគិតថាយើងត្រូវការពី ៣ ទៅ ៦ខែ ដើម្បីពិចារណាលើការសម្រេចចិត្តឡើងវិញនោះទេ ព្រោះយើងបានសម្រេចចិត្តរួចហើយ បើមិនដូច្នោះទេយើងនឹងមិនបានប្តឹងលែងលះទេ» (DW21)។

អនុសាសន៍មួយទៀត គឺសម្រួលនីតិវិធីឲ្យកាន់តែមានភាពងាយស្រួល និងផ្តល់ការគោរពទៅលើគូភាគីដែលកំពុងស្វែងរកការលែងលះឲ្យបានច្រើនជាងនេះ៖ «ពិតណាស់ការលែងលះគួរតែសម្រួលឲ្យកាន់តែងាយស្រួល។ ឧទាហរណ៍...ដំណើរការនីតិវិធីគួរតែលឿន និងផ្តល់ការគោរព ជាជាងការព្យាយាមដាក់ឥទ្ធិពលបញ្ចុះបញ្ចូល និងបន្ទុចបង្អាក់គូភាគីកុំឲ្យស្វែងរកការលែងលះ” (CW1) ។

ជាចុងក្រោយ អ្នកចូលរួមម្នាក់បានឆ្លុះបញ្ចាំងពីហានិភ័យដែលអាចកើតឡើងដល់អ្នកដែលកំពុងជួបប្រទះអំពើហិង្សាបង្កឡើងដោយដៃគូស្និទ្ធស្នាល ដោយសារតែការ អូសបន្លាយពេលនៅក្នុងដំណើរការផ្សះផ្សា និងការលែងលះ៖

*“ខ្ញុំគិតថា វាគួរតែងាយស្រួលជាងនេះ។ បន្ទាប់ពីការផ្សះផ្សា [ម្តងៗ] បុរសអាចត្រឡប់ទៅផ្ទះវិញ ហើយប្រើអំពើហិង្សាលើប្រពន្ធរបស់ពួកគេ។ ដូច្នេះខ្ញុំគិតថាគួរតែមានប្រព័ន្ធការពារជាពិសេសសម្រាប់ស្ត្រី... គួរតែមានកន្លែងសុវត្ថិភាពសម្រាប់ស្ត្រីដែលលែងលះគ្នាដើម្បីឲ្យពួកគេមានអារម្មណ៍ថាមានការការពារ និងក្លាហានក្នុងការបញ្ចេញមតិ” (NDW3)។*



## ៤.២ ការលែងលះក្រៅផ្លូវការ ប្រពៃណី ឬ 'អនីតិសង្វាស់'

នៅក្នុងប្រទេសកម្ពុជា គូស្វាមីភរិយាជាច្រើនរៀបការដោយមិនចុះសំបុត្រអាពាហ៍ពិពាហ៍ស្របច្បាប់ ជាពិសេស នៅតាម តំបន់ជនបទ។ ជាទូទៅអាពាហ៍ពិពាហ៍ទាំងនេះចាត់ទុកថាជា អាពាហ៍ពិពាហ៍ 'ក្រៅផ្លូវការ' 'តាមទំនៀមទម្លាប់' ឬ 'ប្រពៃណី'។ Van der Keur (2014) [១៦] បានពិពណ៌នាអំពីអាពាហ៍ពិពាហ៍ទាំងនេះថាជា អាពាហ៍ពិពាហ៍ 'អនីតីសង្វាស់' និងបានផ្តល់ការយល់ដឹងអំពីរបៀបនៃ 'ការលែងលះអនីតីសង្វាស់' សម្រាប់ប្តីប្រពន្ធខ្មែរដែលគ្មានសំបុត្រ អាពាហ៍ពិពាហ៍ដូចខាងក្រោម៖

*នៅក្នុងប្រទេសកម្ពុជា គូស្វាមីភរិយាជាច្រើនមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅការិយាល័យអត្រានុកូលដ្ឋានទេ ដោយសារពួកគេយល់ឃើញថានីតិវិធីចុះបញ្ជីមានស្មុគ្រស្មាញ... ការខកខាននេះធ្វើឱ្យប៉ះពាល់ជាចម្បងដល់សិទ្ធិស្ត្រី ជាពិសេសអ្នកដែលស្វែងរកការលែងលះនៅពេលក្រោយ។ សិទ្ធិស្ត្រីចំពោះទ្រព្យសម្បត្តិរួម និងប្រាក់ឧបត្ថម្ភរបស់ដៃគូមិនត្រូវបានធានាទេ ដោយសារតែពួកគេមិនត្រូវបានចាត់ទុកថារៀបការស្របច្បាប់ ដូច្នេះហើយគ្មានសិទ្ធិស្របច្បាប់លើទ្រព្យសម្បត្តិរួមជាមួយប្តីអនីតិសង្វាស់របស់ពួកគេ។ ពួកគេក៏ប្រហែលជាគ្មានសិទ្ធិទទួលបានប្រាក់ឧបត្ថម្ភអាហារកិច្ចកូនៗដែរ។*

*មធ្យោបាយដែលប្រើប្រាស់ដើម្បីរំលាយអាពាហ៍ពិពាហ៍អនីតីសង្វាស់ មានលក្ខណៈច្របូកច្របល់ និងផ្តល់លទ្ធផលផ្សេងៗគ្នាសម្រាប់អ្នកចូលរួម... ជាទូទៅគ្មានក្របខ័ណ្ឌច្បាប់ណែនាំដល់ការលែងលះអាពាហ៍ពិពាហ៍អនីតីសង្វាស់នោះទេ។ វាកើតឡើងនៅពេលដែលគូស្វាមីភរិយាមិនស្របច្បាប់មិនអាចទទួលបានការលែងលះតាមផ្លូវច្បាប់តាមរយៈតុលាការ។ ដោយសារតែមានអាពាហ៍ពិពាហ៍អនីតីសង្វាស់កើតឡើង វិស័យយុត្តិធម៌ និងមន្ត្រីរដ្ឋាភិបាលបានស្វែងរកវិធីដើម្បីដោះស្រាយជាមួយនឹងផលវិបាកផ្លូវច្បាប់នៃការលែងលះដៃគូអនីតីសង្វាស់។ ក្រុមប្រឹក្សាឃុំបានបង្កើតដំណោះស្រាយជាក់ស្តែងតាមរយៈការចេញ «លិខិតបញ្ជាក់ការចែកផ្លូវគ្នា»។ លិខិតនេះគ្មានទម្ងន់ផ្លូវច្បាប់ទេ ព្រោះវាមិនផ្អែកលើក្របខ័ណ្ឌច្បាប់។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការអនុវត្តផ្ទាល់ ក្រុមប្រឹក្សាឃុំសង្កាត់នឹងអនុញ្ញាតឱ្យពួកគេរៀបការជាថ្មី ក្រោយពេលដែលពួកគេបានទទួលលិខិតបញ្ជាក់ការចែកផ្លូវគ្នា។*

អ្នកចូលរួមនៅក្នុងការសិក្សានេះដែលបានរៀបការដោយមិនចុះសំបុត្រអាពាហ៍ពិពាហ៍ជាផ្លូវការ ក៏បានពិពណ៌នាអំពីបទពិសោធន៍របស់ពួកគេក្នុងកាស្វែងរកនិងទទួលបានការលែងលះ រួមទាំងបញ្ហាប្រឈមជាក់លាក់ផងដែរ។ វាជារឿងសំខាន់គួរកត់សម្គាល់ថា អ្នកឆ្លើយសំណួរបែបនេះជាច្រើនយល់ថាដំណើរការនេះមានភាពរហ័ស និងសន្សំសំចៃថវិកា ដូចដែលស្ត្រីដែលឆ្លងកាត់ការលែងលះក្រៅផ្លូវការម្នាក់ដែលបានពន្យល់ថា៖

*“[ដំណើរការលែងលះតាមទំនៀមទម្លាប់] មិនពិបាកទេ។ សាលាភូមិរៀបចំឯកសារ និងកិច្ចព្រមព្រៀងលែងលះ យើងគ្រាន់តែផ្តិតមេដៃលើឯកសារលែងលះជាមួយសាក្សី...វាពិតជាលឿនណាស់ ពួកយើងបានផ្តិតមេដៃភ្លាមៗ បន្ទាប់ពីពួកគេរៀបចំឯកសារលែងលះ” (DW9)។*

ជាការពិតណាស់ អ្នកចូលរួមជាច្រើនបានឆ្លុះបញ្ចាំងពីការពិតដែលថា អាពាហ៍ពិពាហ៍តាមប្រពៃណីរបស់ពួកគេគឺងាយស្រួលរំលាយជាងអាពាហ៍ពិពាហ៍ដែលមានច្បាប់ត្រឹមត្រូវ។ នេះរួមបញ្ចូលទាំងអ្នកឆ្លើយតបម្នាក់ដែលបានស្នើសុំការលែងលះតាមទម្លាប់នៅការិយាល័យប៉ុស្តិ៍នគបាលក្នុងតំបន់(DW5) និងម្នាក់ទៀតដែលការលែងលះត្រូវបានរៀបចំដោយគ្រួសារពួកគេផ្ទាល់៖

*“យើងបានរៀបការដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ ដូច្នេះការលែងលះគឺងាយស្រួល។ យើងគ្រាន់តែពិភាក្សាអំពីការលែងលះគ្នាក្នុងគ្រួសារប៉ុណ្ណោះ។ យើងមិនបានទៅសាលាភូមិ ឬតុលាការដើម្បីលែងលះទេ ព្រោះយើងគ្មានសំបុត្រអាពាហ៍ពិពាហ៍ស្របច្បាប់” (DW10)។*

អ្នកចូលរួមម្នាក់ទៀតបានស្នើថា ការលែងលះតាមទម្លាប់គឺងាយស្រួលជាង ដោយសារតែការពិតដែលថាមិនចាំបាច់មានទំនាក់ទំនងជាមួយប្រព័ន្ធតុលាការផ្លូវការ៖

*“ពេលគ្មានសំបុត្រអាពាហ៍ពិពាហ៍វាងាយស្រួល ពីព្រោះយើងមិនចាំបាច់ទៅតុលាការ។ វាងាយស្រួលសម្រាប់ការលែងលះនៅតាមជនបទ ដោយសារតែ [មនុស្សជាច្រើន] គ្មានសំបុត្រអាពាហ៍ពិពាហ៍ ដូច្នេះដំណើរការលែងលះគឺមិនសូវស្មុគស្មាញទេ” (DW22)។*

ខណៈពេលដែលមានអ្នកចូលរួមជាច្រើនបានរាយការណ៍អំពីការយល់ឃើញថា អាពាហ៍ពិពាហ៍តាមប្រពៃណីជាទូទៅ មានភាពងាយស្រួលក្នុងការរំលាយជាងអាពាហ៍ពិពាហ៍ផ្លូវការរនោះ អ្នកខ្លះបានបញ្ជាក់ថាកង្វះឯកសារ និងនីតិវិធីស្តង់ដារ នៅតែអាចធ្វើឱ្យដំណើរការពិបាកខ្លាំង។ ឧទាហរណ៍ អាជ្ញាធរមូលដ្ឋាន នគបាលឬអ្នកដឹកនាំសាសនាតែងតែមានអំណាចខ្លាំងក្នុងការបដិសេធមិនទទួលស្គាល់ការលែងលះតាមទម្លាប់ប្រពៃណី ទោះបីជាភាគីម្ខាង ឬភាគីទាំងពីរស្នើសុំម្តងហើយម្តងទៀតក៏ដោយ។ ស្ត្រីម្នាក់ដែលបានលែងលះក្រៅផ្លូវការបានត្អូញត្អែរថា៖

*«វាមិនមែនជាការងាយស្រួលក្នុងការលែងលះនោះទេ វាពិតជាពិបាកណាស់។ អាជ្ញាធរមិនចង់ឲ្យយើងលែងលះគ្នាទេ ដូច្នេះហើយពួកគេបន្តព្យាយាមផ្សះផ្សាពួកយើង។ ហើយយើងត្រូវចំណាយពេលយ៉ាងច្រើនក្នុងការផ្សះផ្សាគ្នាមុនពេលយើងលែងលះ» (DW14)។*

បន្ថែមលើនេះ អ្នកឆ្លើយសំណួជាបុគ្គលិកអង្គការសង្គមស៊ីវិលម្នាក់បានពោលថា តាមរយៈការសង្កេតរបស់ខ្លួនផ្ទាល់ អាជ្ញាធរមូលដ្ឋានមានអំណាចក្នុងការសម្របសម្រួល ឬបដិសេធសំណើរសុំលែងលះតាមបែបប្រពៃណី។ ចំណុចនេះអាចបង្កផលប៉ះពាល់ដល់ស្ត្រីដោយសារតែអតុល្យភាពអំណាចយេនឌ័រ។ បុគ្គលិកអង្គការសង្គមស៊ីវិលដែលឆ្លងកាត់ការលែងលះគ្នាម្នាក់ដែលធ្វើការងារផ្ទាល់ជាមួយស្ត្រីដែលរស់រានខ្លួជីវិតពី IPV បានគូសបញ្ជាក់ដូចតទៅ៖

*«ក្នុងករណី អាពាហ៍ពិពាហ៍ដែលមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ ភាគីទាំងពីរទៅរកដំណោះស្រាយពីអាជ្ញាធរមូលដ្ឋាន ឬនគបាល។ កន្លែងទាំងនោះជាកន្លែងដែលស្ត្រីជួបការលំបាក ហើយជួនកាលពួកគេត្រូវរងការគំរាមកំហែង និង បំភិតបំភ័យទៀតផង» (CW4)។*

## អនុសាសន៍សម្រាប់កែលម្អនីតិវិធីលែងលះបែបប្រពៃណី៖

ដូចគ្នានឹងអ្នកដែលបានឆ្លងកាត់ការលែងលះតាមនីតិវិធីតុលាការដែរ អ្នកចូលរួមដែលរៀបការបែបប្រពៃណីក៏បានផ្តល់យោបល់សម្រាប់ការកែលម្អដំណើរការលែងលះតាមនីតិវិធីបែបប្រពៃណីផងដែរ។ អនុសាសន៍ទាំងអស់នេះគឺផ្តោតលើ តម្រូវការក្នុងការសម្រួលឱ្យដំណើរការលែងលះកាន់តែមានភាពងាយស្រួលដូចដែលអ្នកចូលរួមម្នាក់បានពោលថា៖

“ខ្ញុំគិតថារយៈពេលដំណើរការគួរតែកាន់តែងាយស្រួល និងប្រើពេលវេលាតិចជាងនេះ។ ខ្ញុំមិនចង់ឱ្យដំណើរការចំណាយពេលយូរបែបនេះទេ» (DW32)។

## ៤.៣ លក្ខណៈប្រែប្រួលប្រជាសាស្ត្រ

ការឆ្លើយតបរបស់អ្នកចូលរួមក្នុងអំឡុងពេលសម្ភាសន៍បានបង្ហាញថា បទពិសោធន៍នៃការលែងលះនៅក្នុងប្រទេសកម្ពុជា ជារឿយៗប្រែប្រួលទៅតាមស្ថានភាពប្រជាសាស្ត្រជាក់លាក់។ ស្ថានភាពទាំងនេះរួមមានថា តើបុគ្គលនោះរស់នៅតំបន់ ជនបទ ឬទីក្រុង មានការអប់រំកម្រិតណា មានប្រាក់ចំណូលគ្រួសារកម្រិតណា អាយុប៉ុន្មាន ព្រមទាំងថា តើពួកគេមានកូន ជាមួយគ្នា ឬអត់។ ផ្នែកនេះផ្តល់ការបរិយាយដោយសង្ខេបពីការយល់ឃើញអំពីផលប៉ះពាល់នៃស្ថានភាពទាំងអស់នេះ ។

### បទពិសោធន៍អ្នកជនបទ និងអ្នកទីក្រុង

មានមតិខុសៗគ្នាក្នុងចំណោមអ្នកចូលរួមថា តើទីតាំងភូមិសាស្ត្រដែលដៃគូកំពុងរស់នៅអាចផ្តល់ភាពងាយស្រួល ឬអាចបង្កការពិបាកដល់ពួកគេក្នុងការទទួលបានការលែងលះ។ អ្នកខ្លះបានបង្ហាញទស្សនៈថា ការលែងលះគឺងាយស្រួលក្នុងការទទួលបាននៅតំបន់ជនបទដោយសារតែសាមីខ្លួន និងអាជ្ញាធរមានទំនាក់ទំនង និងស្គាល់គ្នា ព្រោះពួកគេរស់នៅក្នុងសហគមន៍ដូចគ្នា៖

*“ភូមិយើងរស់នៅតូចបើធៀបនឹងទីក្រុង ដូច្នេះយើងស្គាល់មេភូមិ និងអាជ្ញាធរផ្ទាល់ យើងអាចស្នើសុំការលែងលះដោយងាយស្រួល។ ខ្ញុំគិតថាអ្នកទីក្រុងអាចពិបាកក្នុងការទទួលបានការលែងលះ ដោយសារតែមានប្រជាជនជាច្រើនរស់នៅក្នុងស្រុកនិមួយៗ...” (DW3) ។*

អ្នកផ្សេងទៀតបានលើកឡើងថា ដោយសារការរៀបអាពាហ៍ពិពាហ៍តាមទំនៀមទម្លាប់គឺជារឿងធម្មតានៅក្នុងតំបន់ជនបទ ជាទូទៅការលែងលះនៅក្នុងតំបន់ទាំងនេះក៏កាន់តែងាយស្រួលដែរ។ ឧទាហរណ៍ អ្នកចូលរួមម្នាក់បានពោលបញ្ជាក់ថា "វាងាយស្រួលនៅតំបន់ជនបទដោយសារតែ ដៃគូរៀបការជាច្រើន មិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ផ្លូវច្បាប់។ ដូច្នេះ ពួកគេគ្រាន់តែទៅសាលាភូមិដើម្បីសុំលែងលះ ហើយដំណើរការលែងលះនេះមិនសូវស្មុគស្មាញ និងធ្វើបានយ៉ាងលឿន" (DW21)។ អ្នកចូលរួមម្នាក់ទៀតផ្តល់ការសង្កេតឃើញស្រដៀងគ្នាថា "ដោយសារតែគ្មាននីតិវិធីច្រើននៅសាលាភូមិ នៅ តំបន់ជនបទ ប្រជាជនមិនចាំបាច់ចំណាយពេល ឬលុយច្រើនដើម្បីលែងលះគ្នានោះទេ" (DW16)។



ម៉្យាងវិញទៀត អ្នកឆ្លើយសំណួរជាច្រើនបានលើកឡើងថាជារឿយៗថា ដោយសារតែហេតុផលមួយចំនួននោះអ្នកជនបទអាចជួបការពិបាកក្នុងការទទួលបានការលែងលះជាងអ្នកទីក្រុង។ ស្ថានភាពទីមួយគឺ បញ្ហាប្រឈមផ្នែកមធ្យោបាយធ្វើដំណើរទៅមកដើម្បីប្រើប្រាស់ប្រព័ន្ធតុលាការសម្រាប់អ្នករស់នៅជនបទដែលចុះសំបុត្រអាពាហ៍ពិពាហ៍ផ្លូវការ៖

> *“ប្រជាជននៅតាមជនបទ... មិនដឹងច្រើនអំពីច្បាប់ ហើយត្រូវធ្វើដំណើរឆ្ងាយទៅទីក្រុងទៅតុលាការប្រសិនបើចង់លែងលះ” (DW11)។* ***អ្នកចូលរួមម្នាក់ទៀតបានពន្យល់ថា*** *"វាងាយស្រួលសម្រាប់អ្នកទីក្រុងក្នុងការទទួលបានការលែងលះ ពីព្រោះ ងាយស្រួលក្នុងការស្វែងរកជំនួយពីមេធាវីជាងនៅតំបន់ជនបទ" (NDW4)។*

ហេតុផលទីពីរ មនុស្សជាច្រើនយល់ឃើញថាស្ត្រីដែលរស់នៅតាមជនបទទទួលរងនូវភាពអាម៉ាស់ និងការមាក់ងាយខ្លាំងជាងអ្នកទីក្រុង បន្ទាប់ពីពួកគេស្វែងរកការលែងលះ។ ការមាក់ងាយនេះអាចក្លាយទៅជារបាំងឧបសគ្គដ៏ចម្បងដល់ស្ត្រីជនបទនៅពេលស្វែងរកព័ត៌មាន និងក្នុងអំឡុងពេលដំណើរការលែងលះ។ ជាការពិតណាស់ ក្នុងចំណោមអ្នកឆ្លើយតបការស្ទង់មតិអនឡាញ ៤៤% យល់ថាស្ត្រីដែលឆ្លងកាត់ការលែងលះដែលរស់នៅក្នុងតំបន់ជនបទប្រឈមនឹងការមាក់ងាយ និងការវិនិច្ឆ័យច្រើនជាងអ្នកនៅក្នុងទីក្រុង ខណៈដែលមានតែ ៨% ប៉ុណ្ណោះដែលបង្ហាញការយល់ឃើញផ្ទុយពីនេះ។

អ្នកឆ្លើយតបសំភាសន៍ផ្សេងទៀតបានសង្កេតឃើញថា ជាទូទៅស្ត្រីនៅទីក្រុងទទួលបានការអប់រំ និងប្រាក់ចំណូលខ្ពស់ជាងស្ត្រីនៅតាមជនបទ ដែលធ្វើឱ្យស្ត្រីរស់នៅក្នុងទីក្រុងអាចទទួលបានការលែងលះដោយងាយស្រួល៖«ស្ត្រីនៅក្នុងទីក្រុងមានអំណាចច្រើនជាងក្នុងការសម្រេចចិត្ត ដោយសារតែពួកគេមានស្ថានភាពហិរញ្ញវត្ថុល្អប្រសើរ។ សម្រាប់ស្ត្រីដែល មានប្រាក់ចំណូលផ្ទាល់ខ្លួន វាងាយស្រួលសម្រាប់ពួកគេក្នុងការស្វែងរកការលែងលះ”(NDW3)។ ជាចុងក្រោយ អ្នកឆ្លើយតបដែលជាបុគ្គលិកអង្គការសង្គមស៊ីវិលម្នាក់បានពោលដោយសង្ខេបថា “ស្ត្រីនៅក្នុងទីក្រុងមានភាពងាយស្រួលក្នុងការលែងលះជាងអ្នកនៅជនបទ ដោយសារតែលទ្ធភាពទទួលបានព័ត៌មានបណ្ដាញសង្គម និងធនធានហិរញ្ញវត្ថុ របស់ពួកគេ” (CW2)។

**អ្នកតំបន់ជនបទ និងទីក្រុង៖ តើអ្នកគិតថានរណាប្រឈមនឹងការមាក់ងាយ និងវិនិច្ឆ័យពីសង្គមច្រើនជាងក្រោយពេលលែងលះ?**



## បទពិសោធន៍មនុស្សវ័យក្មេង និងវ័យចំណាស់

ខណៈពេលដែលមានមតិខុសៗគ្នាអំពីថា តើស្ត្រីនៅជនបទ ឬស្ត្រីនៅទីក្រុងដែលមានភាពងាយស្រួលជាងក្នុងការទទួលបានការលែងលះនោះ អ្នកឆ្លើយសម្ភាសន៍មានមតិជាឯកច្ឆ័ន្ទក្នុងទស្សនៈថា ការលែងលះគឺងាយស្រួលទទួលបានសម្រាប់ស្ត្រីវ័យក្មេងជាងស្ត្រីវ័យចំណាស់ជំនាន់មុន។ ៥៨%នៃអ្នកចូលរួមការស្ទង់មតិអនឡាញបានឆ្លើយតប ថាមនុស្សជំនាន់មុនទំនងជាវិនិច្ឆ័យលើអ្នកដែលឆ្លងកាត់ការលែងលះជាង បើប្រៀបធៀបទៅនឹង១៧% សម្រាប់មនុស្សវ័យក្មេង។ យោងតាមសម្តីរបស់អ្នកផ្តល់សម្ភាសន៍ជាស្ត្រីលែងលះម្នាក់ស្ថានភាពនេះប្រហែលជាពីព្រោះ៖

*«មនុស្សជំនាន់មុនតែងតែព្យាយាមផ្សះផ្សាប្តីប្រពន្ធ ទោះបីមានអំពើហិង្សាក្នុងគ្រួសារក៏ដោយ ក៏ពួកគេមិនចង់ឲ្យកូនៗលែងលះដែរ» (DW1)។*

### គម្លាតនៃជំនាន់រស់នៅ៖ តើអ្នកគិតថានរណាដែលទំនងជាវិនិច្ឆ័យទៅលើអ្នកដែលលែងលះ?




ផ្ទុយទៅវិញ អ្នកឆ្លើយសំណួរជាច្រើនបានលើកឡើងពីហេតុផលជាច្រើនដែលជួយឲ្យក្មេងជំនាន់ក្រោយអាចទទួលបានការលែងលះដោយងាយស្រួល។ ពួកគេក៏ឆ្លុះបញ្ចាំងពីទិដ្ឋភាពជាក់ស្តែងដែលយុវជនកម្ពុជាមានផ្នត់គំនិតសេរីនិយមចំពោះ ការលែងលះផងដែរ។ អ្នកឆ្លើយសំណួរម្នាក់បានពោលថាផ្នត់គំនិតសេរីនិយមនេះជំរុញឲ្យពួកគេមើលឃើញថាការលែងលះគឺជារឿង "វិជ្ជមាន" មួយ៖

*«ខ្ញុំគិតថាយុវជនមានទស្សនៈវិជ្ជមានចំពោះការលែងលះ ហើយយល់ដឹងថាមានហេតុផលជាច្រើនដែលនាំទៅរក [លទ្ធផលនោះ]។ ពួកគេក៏ដឹងពីគុណសម្បត្តិ និងគុណវិបត្តិនៃការលែងលះ ហើយពួកគេមានចិត្តទូលាយជាង បើធៀបនឹងមនុស្សជំនាន់មុន» (DW10) ។*



ស្រដៀងគ្នាទៅនឹងស្ត្រីនៅទីក្រុងដែលបានពិពណ៌នាខាងលើ ស្ត្រីវ័យក្មេង ក៏មានលទ្ធភាពទទួលបានប្រាក់ចំណូលខ្ពស់ និងទទួលបានការអប់រំ និងព័ត៌មានប្រសើរជាងស្ត្រីវ័យចំណាស់។ អ្នកឆ្លើយសំណួរជាច្រើនបានផ្តល់ទស្សនៈថា យុវនារីមានទំនោរ «គិតថាការលែងលះគឺជារឿងធម្មតា» ពីព្រោះពួកគេអាច «រស់នៅដោយខ្លួនឯង និងអាចចិញ្ចឹមខ្លួន...» (CW5)។ ជាមួយនឹង "ឯករាជ្យភាពផ្នែកសេដ្ឋកិច្ចខ្លាំងជាងមនុស្សជំនាន់មុន ស្ត្រីវ័យក្មេងមិនខ្លាចការលែងលះទេ" (ibid)។ ផ្ទុយទៅវិញ អ្នកឆ្លើយសំណួរជាច្រើនបានផ្តល់មតិថាចំពោះស្ត្រីវ័យចំណាស់ពួកគេ "ទំនងជាមិនសូវលែងលះ" ដោយសារតែ "ពួកគេមានកម្រិតនៃការអប់រំទាប ហើយមិនប្រកបការងារទទួលបានប្រាក់កម្រៃ ដូច្នេះពួកគេត្រូវតែពឹងផ្អែកលើប្តីរបស់ពួកគេ" (DW9) ។

ដូចនឹងការដែលមនុស្សវ័យក្មេងមាន "លទ្ធភាពទទួលបានការអប់រំ ព័ត៌មាន និងឯករាជ្យភាពសេដ្ឋកិច្ច" អ្នកឆ្លើយសំណួរជាបុគ្គលិកអង្គការសង្គមស៊ីវិលម្នាក់ពោលថា ពួកគេក៏ "គិតខុសពីមនុស្សចាស់" ទាក់ទងនឹង "ការស៊ូទ្រាំគ្រប់ទម្រង់នៃអំពើហិង្សាក្នុងអាពាហ៍ពិពាហ៍ដើម្បីរក្សាភាពសុខដុមរមនាក្នុងគ្រួសារ"(CW3)។ អ្នកឆ្លើយសំណួរដដែលនោះក៏បាន ពោលបន្តថា “ខណៈពេលដែលមនុស្សចាស់ផ្តោតលើការរក្សាទ្រព្យសម្បត្តិ និងកេរ្តិ៍ឈ្មោះ... យុវជនហាក់ដូចជាផ្តល់អាទិភាពដល់សុខភាពផ្លូវចិត្តរបស់ពួកគេជាជាងការស៊ូទ្រាំនឹងអំពើហិង្សា... [ពួកគេ] មើលឃើញថាការលែងលះជាជម្រើសមួយ ប្រសិនបើពួកគេមិនចុះសម្រុងជាមួយដៃគូរបស់ពួកគេ” (CW3)។



## ៤.៤ ស្ថានភាពជីវិតក្រោយការលែងលះ

ក្រោយពីឈ្វេងយល់ពីបទពិសោធន៍អ្នកចូលរួមស្ត្រីបានជួបប្រទះនៅក្នុងសង្គម ឧបសគ្គផ្នែកហិរញ្ញវត្ថុនិងវិធានការរដ្ឋបាល នៅក្នុងដំណើរការលែងលះនៅកម្ពុជា ចំណុចបន្ទាប់នៃរបាយការណ៍នេះនឹងត្រួតពិនិត្យមើលផលប៉ះពាល់រយៈពេលវែង ចំនួនដែលស្ត្រីជួបប្រទះនៅក្នុងរយៈពេលជាច្រើនឆ្នាំបន្ទាប់ពីលែងលះ។ ការពិភាក្សាត្រូវបានបែងចែកទៅជាបទពិសោធន៍ ឬផលប៉ះពាល់អវិជ្ជមាន – ឧទាហរណ៍ ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច វិសមាមាត្រនៃបន្ទុកការងារថែទាំគ្មានប្រាក់កម្រៃ និងការមាក់ងាយសង្គមយូរអង្វែង – និងចំណុចវិជ្ជមាន រួមទាំងការកើនឡើងនៃសេរីភាព និងស្វ័យភាព និងការរស់នៅប្រចាំថ្ងៃដោយគ្មានអំពើហិង្សា និងការភ័យខ្លាច។

## ផលប៉ះពាលអវិជ្ជមាន

### ភាពអាម៉ាស់ និងការមាក់ងាយ

ដូចដែលបានពិភាក្សារួចមកហើយនៅក្នុងរបាយការណ៍នេះទាំងស្រុង ភាពអាម៉ាស់ និងការមាក់ងាយក្នុងសង្គមនៅតែបន្តកើតឡើងចំពោះការលែងលះនៅក្នុងបរិបទកម្ពុជា ទោះបីជាការលែងលះហាក់ត្រូវបានទទួលយកដោយសង្គម និងមានការកើនឡើងក៏ដោយ។ នៅពេលដែលសួរថា តើការលែងលះអាចបង្កផលប៉ះពាល់ដល់ជីវិតរបស់ពួកគេប៉ុន្មានឆ្នាំបន្ទាប់ពីការលែងលះ អ្នកចូលរួមស្ត្រីជាច្រើនបានពន្យល់ថា កេរ្តិ៍ឈ្មោះ និងមុខមាត់របស់ពួកគេនៅតែអាប់អោននៅក្នុងក្រសែភ្នែកសហគមន៍។ ស្ត្រីម្នាក់បានរាយការណ៍ថា “ក្នុងនាមជាស្ត្រី ការលែងលះបានធ្វើឲ្យខូចមុខមាត់របស់ខ្ញុំ” ខណៈដែលស្វាមីរបស់នាងបានរងផលប៉ះពាល់ “បន្តិចបន្តួច”(DW3)។ អ្នកចូលរួមដដែលនេះបានពន្យល់ថានេះក៏ព្រោះតែ “សម្រាប់ស្ត្រី មនុស្សម្នានិយាយថាពេលក្រណាត់សប្រឡាក់វាមិនអាចសម្អាតបានទៀតទេ”។ ការអត្ថាធិប្បាយនេះសំដៅលើសុភាសិតខ្មែរដ៏ល្បីមួយដែលពណ៌នាបុរសថាគឺជាមាសដែលកេរ្តិ៍ឈ្មោះរបស់ពួកគេអាចស្អាតស្អំជានិច្ច ខណៈដែលប្រៀបធៀបស្ត្រីទៅនឹងក្រណាត់ស ដូច្នេះស្ត្រីត្រូវតែឧស្សាហ៍ការពារខ្លួនពី 'ការប្រឡាក់' ណាមួយ។

សម្ពាធដែលតម្រូវឲ្យស្ត្រីរក្សាភាពបរិសុទ្ធនៅក្នុងក្រសែភ្នែករបស់សហគមន៍នេះ កើតឡើងនិងផ្សាភ្ជាប់យ៉ាងជិតស្និទ្ធជាមួយនឹងវប្បធម៌ព្រហ្មចារីដែលបានពិភាក្សានៅក្នុងផ្នែកទី៣.២។ អ្នកចូលរួមម្នាក់បានពិភាក្សាអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់នាង៖ «តាំងពីខ្ញុំលែងលះគ្នា ខ្ញុំក៏បានទទួលការរិនិច្ឆ័យពីអ្នកជុំវិញខ្លួនដែរ... ពួកគេមិនយល់ពីអារម្មណ៍របស់ស្ត្រី ដែលលែងលះគ្នានោះទេ” (DW11)។ អ្នកឆ្លើយតបម្នាក់ទៀតបានពោលស្រដៀងគ្នាថានាង "បានទទួលការរិនិច្ឆ័យជា ច្រើនពីសាច់ញាតិ" (DW13) ខណៈពេលដែលអ្នកផ្សេងទៀតបាននិយាយថា "មនុស្សជាច្រើនមើលងាយខ្ញុំព្រោះខ្ញុំគ្មានគ្រួសារពេញលេញ មួយ" (DW6)។

អ្នកឆ្លើយសំណួរជាច្រើនបានរាយការណ៍ថា មនុស្សជាច្រើនមិនសូវទុកចិត្តពួកគេទេ នៅពេលដែលពួកគេចំណាយពេលជាមួយបុរសដែលរៀបការហើយ ពីព្រោះសង្គមប្រកាន់គំនិតថាស្ត្រីដែលឆ្លងកាត់ការលែងលះគ្នាគឺជាស្រីចិត្តងាយ។ ស្ត្រីម្នាក់បានឆ្លើយពន្យល់ថា៖ *«ពាក្យ'មេម៉ាយ' (ស្ត្រីលែងលះ) គឺដូចជារបួសដែលមិនជាសះនៅក្នុងជីវិតរបស់យើង។ យើងត្រូវតែប្រយ័ត្នរាល់ពេលដែលយើងនិយាយ ឬលេងសើចជាមួយនរណាម្នាក់ ព្រោះមនុស្សអាចនឹងវិនិច្ឆ័យយើង”(DW20)។*
អ្នកឆ្លើយតបដដែលនេះ បានរៀបរាប់ថាការដែលនាងទៅលេងផ្ទះមិត្តភក្តិដែលរៀបការរួចញឹកញាប់នោះ *“មនុស្សម្នាអាច និយាយដើមពីក្រោយខ្នងថាខ្ញុំប្រហែលជាទៅលេងនាងញឹកញាប់ព្រោះខ្ញុំចង់ល្បួងប្ដីមិត្តភក្តិ” ឬ បើនាងនិយាយជាមួយ មិត្តភ័ក្តិប្រុស “ប្រពន្ធគាត់មិនចូលចិត្តទេ ព្រោះខ្ញុំជាស្ត្រីលែងលះ” (DW20)។ អ្នកឆ្លើយតបម្នាក់ទៀតបានពិពណ៌នាស្រដៀងគ្នាថា "ជាធម្មតាមនុស្សតែងតែសម្លឹងមើលខ្ញុំ ឬសម្លក់ខ្ញុំនៅពេលដែលពួកគេឃើញខ្ញុំនិយាយជាមួយស្វាមីរបស់ ពួកគេ... នៅពេលណាដែលមនុស្សឮពាក្យ 'មេម៉ាយ' ពួកគេសន្មតថាយើងជាស្រីមិនល្អ" (DW16)។*

អ្នកឆ្លើយតបជាបុគ្គលិកCSOម្នាក់បានលើកឡើងថា បទដ្ឋានគ្រោះថ្នាក់ទាក់ទងនឹងការសង្ស័យលើស្វ័យភាពផ្លូវភេទរបស់ស្ត្រីក្រោយការលែងលះទាំងអស់នេះ "ចាក់ឫសយ៉ាងជ្រៅនៅក្នុងគុណតម្លៃវប្បធម៌របស់យើង...” ហើយបានចែករំលែកថា “ខ្ញុំផ្ទាល់បានជួបប្រទះការមាក់ងាយ និងរងការរិនិច្ឆ័យជាច្រើនតាំងពីការលែងលះរបស់ខ្ញុំ” (CW1)។

ចំពោះថាតើបុរសត្រូវរងការអាម៉ាស់ក្នុងកម្រិតដូចគ្នាទាក់ទងនឹងការលែងលះដែរ ឬទេនោះ អ្នកចូលរួមម្នាក់បានពន្យល់ថា យោងតាមបទពិសោធន៍របស់នាងផ្ទាល់ស្ថានភាពគឺខុសគ្នាឆ្ងាយណាស់៖ «ខ្ញុំគិតថាគាត់ត្រូវបានក្រុមគ្រួសារស្ដីបន្ទោស ប៉ុន្តែការស្ដីបន្ទោសដែលគាត់បានទទួលគឺតិចជាងខ្ញុំបានទទួលទេ។ គ្រួសារគាត់មិនខ្វល់ខ្វាយច្រើនទេ ព្រោះពួកគេគិតថា បុរសដែលលែងលះអាចស្វែងរកដៃគូថ្មីបានយ៉ាងងាយស្រួល” (DW15)។ អ្នកចូលរួមម្នាក់ទៀតបង្ហាញការយល់ស្របដោយគូសបញ្ជាក់ថាតាមបទពិសោធន៍របស់នាង «ខ្ញុំនឹងនិយាយថា គាត់ទទួលបានការរិនិច្ឆ័យតិចជាងខ្ញុំទៅទៀត ព្រោះគាត់ជាបុរស» (CW1)។

អ្នកឆ្លើយតបបុរសជាច្រើនដែលឆ្លងកាត់ការលែងលះក៏បានយល់ស្របថា ស្ត្រីត្រូវបានគេតាមឃ្លាំមើល និងវិនិច្ឆ័យតឹងរ៉ឹងជាងបុរសបន្ទាប់ពីការលែងលះ។ បុរសម្នាក់ពន្យល់ថា "ខ្ញុំគិតថាអតីតប្រពន្ធរបស់ខ្ញុំទទួលបានការវិនិច្ឆ័យច្រើនជាងខ្ញុំ" (DM3) ហើយបុរសម្នាក់ទៀតក៏បានបញ្ជាក់ដែរថា "យើងជាបុរយើងអាចយកប្រពន្ធមួយផ្សេងទៀតពេលណាដែលយើងចង់បាន ប៉ុន្តែសម្រាប់ស្ត្រីវាពិបាកជាង។ គ្មាននរណាម្នាក់ចង់រៀបការជាមួយស្ត្រីដែលលែងលះនោះទេ ជាពិសេសស្ត្រីលែងលះដែលមានកូន» (DM1)។

## ការបាក់ស្បាត និងតស៊ូផ្លូវអារម្មណ៍

ចំណុចមួយទៀតដែលអ្នកឆ្លើយតបបានរាយការណ៍ទាក់ទងនឹងផលប៉ះពាល់អវិជ្ជមានក្នុងរយៈពេលវែងបន្ទាប់ពីលែងលះ គឺទាក់ទងនឹងការបាក់ស្បាត (ដែលជាស្ថានភាពដ៏ធ្ងន់ធ្ងរ ជាពិសេសសម្រាប់អ្នករស់រានជីវិតពីIPV) និងទុក្ខព្រួយផ្លូវចិត្ត។ អារម្មណ៍បន្ទោសខ្លួនឯង អារម្មណ៍មន្ទិល និងអារម្មណ៍ថាបានប្រព្រឹត្តកំហុសឆ្គងបានកើតឡើងចំពោះអ្នកឆ្លើយសំណួរ ជាច្រើនក្នុងរយៈពេលច្រើនឆ្នាំក្រោយការលែងលះរបស់ពួកគេ។ អ្នកឆ្លើយសំណួរម្នាក់បានពន្យល់ថា៖

*«ខ្ញុំមានអារម្មណ៍ធ្លាក់ទឹកចិត្ត។ នៅពេលខ្ញុំឃើញគ្រួសារអ្នកដទៃ ខ្ញុំបន្ទោសខ្លួនឯងចំពោះការលែងលះ [ទោះបីជា] គាត់ប្រើអំពើហិង្សាលើខ្ញុំក៏ដោយ» (DW6)។*

ស្ថានភាពទុក្ខព្រួយផ្លូវចិត្តទាំងនេះកាន់តែធ្ងន់ធ្ងរឡើង ដោយសារតែការវិនិច្ឆ័យតតឈប់ឈរពីសមាជិកគ្រួសារ ឬសមាជិកសហគមន៍ផ្សេងទៀត។ អ្នកចូលរួមជាច្រើនបានរាយការណ៍ថា ការវិនិច្ឆ័យនេះបានបង្កផលប៉ះពាល់ដល់សុខភាពផ្លូវចិត្ត របស់ពួកគេ។ អ្នកចូលរួមម្នាក់បានពិពណ៌នាថាចាប់តាំងពីការលែងលះគ្នាការវិនិច្ឆ័យនេះបានធ្វើឲ្យ"សុខភាពផ្លូវចិត្តរបស់ ខ្ញុំមិនល្អ ខ្ញុំឆាប់ខឹង ហើយមិនសូវមានការអត់ធ្មត់" (DW12)។ អ្នកចូលរួមម្នាក់ទៀតបានប្រាប់ថា “...មតិនិងការវិនិច្ឆ័យរបស់មនុស្សម្នានៅតែមានឥទ្ធិពលលើអារម្មណ៍របស់ខ្ញុំ។ ក្នុងអំឡុងពេលប៉ុន្មានខែដំបូង ទោះបីជាខ្ញុំបានបន្តរស់នៅធម្មតាក៏ដោយ... ខ្ញុំស្រកទម្ងន់ជាច្រើន» (CW3)។

មានការយល់ឃើញថាសម្រាប់បុរស ពួកគេអាចចំណាយពេលត្រឹមតែ "ប្រាំមួយខែទៅមួយឆ្នាំ" ប៉ុណ្ណោះ ដើម្បីសះស្បើយពីការឈឺចាប់នៃការលែងលះ ហើយថា "បុរសអាចបន្តនិងស្វែងរកដៃគូថ្មីបានលឿនជាងស្ត្រី" (DW8)។ អ្នកឆ្លើយតបជាបុគ្គលិកអង្គការម្នាក់បានរាយការណ៍ថា "ខ្ញុំមិនគិតថាវាត្រូវការពេលយូរសម្រាប់បុរស [ដើម្បីព្យាបាល]" ដោយពន្យល់ថា នៅក្នុងករណីរបស់នាង "អតីតស្វាមីរបស់ខ្ញុំមិនមានការឈឺចាប់ឬរងទុក្ខវេទនាអីទេ បន្ទាប់ពីការលែងលះ [និង] បានចាប់ផ្ដើមជីវិតថ្មីជាមួយស្ត្រីកំណាន់របស់គាត់ភ្លាមៗ” (CW2) ។

### តើអ្នកគិតថា នរណាដែលទទួលរងការប៉ះទង្គិចផ្លូវអារម្មណ៍ច្រើនជាងពីការលែងលះ?



## ផលប៉ះពាល់លើកុមារ

ផលប៉ះពាល់អវិជ្ជមានដ៏សំខាន់មួយនៃការលែងលះដែលស្ត្រីនៅក្នុងប្រទេសកម្ពុជាបានជួបប្រទះគឺ ការយល់ឃើញថាដំណើរការលែងលះនឹងបង្កផលប៉ះពាល់ដល់កូនៗរបស់ពួកគេ។ អ្នកចូលរួមជាច្រើនបានពណ៌នាអំពីកំហុសឆ្គងទាក់ទងនឹងស្ថានភាពវិបត្តិផ្លូវចិត្ត និងផ្លូវអារម្មណ៍ដែលកូនៗរបស់ពួកគេជួបប្រទះ។ អ្នកចូលរួមម្នាក់បានពន្យល់ថា “ប្រសិនបើយើងគ្មានកូនក្នុងអំឡុងអាពាហ៍ពិពាហ៍ វានឹងប្រសើរជាងនេះ។ ខ្ញុំសោកស្តាយដែលយើងមានកូន ហើយលែងលះគ្នា ព្រោះខ្ញុំមានអារម្មណ៍មិនល្អទេនៅពេលកូនខ្ញុំគ្មានឪពុក" (DW13)។ អ្នកចូលរួមដដែលបានបន្តថា "ការលែងលះបានប៉ះពាល់ ដល់អារម្មណ៍របស់កូនខ្ញុំយ៉ាងធ្ងន់ធ្ងរ"។

ស្ត្រីដែលលែងលះគ្នាមួយចំនួនបានផ្តល់ដំបូន្មានថា ឥទ្ធិពលផលប៉ះពាល់លើកូនរបស់ពួកគេគឺធ្ងន់ធ្ងរនិងយូរអង្វែង។ អ្នកចូលរួមជាបុគ្គលិកអង្គការម្នាក់បានពណ៌នាថា "កូនដេកយំរហូតដេកលក់" និង "ក្លាយជាមនុស្សឯកកោ និងមិនសូវមានទំនុកចិត្តលើខ្លួនឯង" (CW4)។ នាងបានរាយការណ៍ថា កូនប្រុសច្បងរបស់នាង "ចាប់ផ្តើមធ្វើខ្លួនដូចជាឪពុករបស់ខ្ញុំ ឬប្តីរបស់ខ្ញុំ។ គាត់ចង់គ្រប់គ្រងខ្ញុំ ហើយតែងតែសួរខ្ញុំថា តើខ្ញុំទៅណាខ្លះជាដើម។" នាងបានរាយការណ៍ថាច្រើនឆ្នាំក្រោយការលែងលះអ្វីៗបានក្លាយទៅជា "ប្រសើរជាងមុនបន្តិច" ហើយថា កូនៗរបស់នាងមានភាពរស់រាយច្រើនជាងមុន។ ទោះជាយ៉ាងណាក៏ដោយបញ្ហាប្រឈមនៃការចិញ្ចឹមកូនតែម្នាក់ឯង ខណៈដែលនាងត្រូវរកប្រាក់ចំណូលដែរនោះមានន័យថានាងមានពេលតិចតួចសម្រាប់ចំណាយជាមួយពួកគេ ហើយស្ថានភាពនៃកង្វះពេលវេលានេះនៅតែជាបញ្ហាប្រឈម។



## ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ

ស្រ្តីមានកូនជាច្រើននាក់ដែលចូលរួមផ្តល់សម្ភាសន៍ បានរាយការណ៍ថា ពួកគេត្រូវបានបង្ខំឱ្យរ៉ាប់រងបន្ទុកហិរញ្ញវត្ថុយ៉ាងធ្ងន់ធ្ងរក្នុងរយៈពេលប៉ុន្មានឆ្នាំបន្ទាប់ពីការលែងលះ។ មនុស្សជាច្រើនបានពិពណ៌នាថាត្រូវ "រកប្រាក់ចិញ្ចឹមកូនតែម្នាក់ឯង" ដូច្នេះពួកគេ "ព្រួយបារម្ភពីបញ្ហាថវិកាគ្រប់ពេលវេលាទាំងអស់"(DW20)។ អ្នកឆ្លើយតបម្នាក់ដែលមានកូន ៥នាក់ បានពិពណ៌នាអំពីការព្រួយបារម្ភរបស់នាងអំពីលទ្ធភាពចិញ្ចឹមកូន និងផ្គត់ផ្គង់ការអប់រំរបស់ពួកគេតែម្នាក់ឯង (DW4) ខណៈដែលអ្នកឆ្លើយតបម្នាក់បង្ហាញភាពសោកសៅថា នាងត្រូវលក់គ្រឿងអលង្ការរបស់នាងទាំងអស់ដើម្បីចិញ្ចឹមកូន ចាប់តាំងពីការលែងលះ(DW6)។ អ្នកចូលរួមខាងក្រោមបានពណ៌នាថាគេត្រូវរ៉ាប់រងបន្ទុកបំណុលដែលបានខ្ចីធនាគារ ក៏ដូចជារ៉ាប់រងបន្ទុកចំណាយលើកូនទាំងស្រុង៖

> *“គាត់បានដកខ្លួនចេញពីទំនួលខុសត្រូវទាំងអស់ ហើយបានទុកឲ្យខ្ញុំរ៉ាប់រងទាំងស្រុងចាប់តាំងពីលែងលះ។ គាត់មិនខ្វល់ពីអ្វីទាំងអស់។ គាត់បានទុកបន្ទុកទាំងអស់មកលើខ្ញុំតែម្នាក់ឯង។ ខ្ញុំត្រូវមើលថែកូន ខ្ញុំត្រូវធ្វើការដើម្បីសងបំណុលតែម្នាក់ឯង... ខ្ញុំនៅតែមើលថែគ្រួសារទាំងមូល ហើយបារម្ភពីការចំណាយប្រចាំថ្ងៃ។ វាពិតជាពិបាកសម្រាប់ខ្ញុំ” (DW19) ។*

ទោះបីជាប្រាក់ឧបត្ថម្ភដៃគូ និងកាតព្វកិច្ចអាហារកិច្ចត្រូវបានចែងនៅក្នុងច្បាប់កម្ពុជានៅក្នុងទប្បញ្ញត្តិច្បាប់ជាក់លាក់[1] អ្នកឆ្លើយសំណួរជាច្រើនបានរាយការណ៍ថា អតីតស្វាមីរបស់ពួកគេបានបដិសេធទាំងស្រុងក្នុងការផ្តល់ជំនួយហិរញ្ញវត្ថុ ឬជំនួយផ្សេងទៀតក្នុងរូបភាពណាមួយដល់ពួកគេបន្ទាប់ពីពួកគេបែកគ្នា៖

> *“កូនសម្រេចចិត្តរស់នៅជាមួយខ្ញុំ ហើយអតីតស្វាមីរបស់ខ្ញុំបានសន្យាថានឹងបង់ប្រាក់ចិញ្ចឹមកូន និងប្រាក់សម្រាប់មើលថែសុខុមាលភាពរបស់កូនយើងនៅក្នុងកិច្ចព្រមព្រៀងលែងលះ។ ទោះជាយ៉ាងណាគាត់មិនបានផ្តល់ប្រាក់ឧបត្ថម្ភដល់កូនណាមួយឡើយ ចាប់តាំងពីការលែងលះមក។ ៧ឆ្នាំហើយ! ខ្ញុំត្រូវប្រឹងប្រែងដើម្បីរ៉ាប់រងការសិក្សារបស់កូនខ្ញុំ» (CW4)។*

1 សម្រាប់ប្រាក់ឧបត្ថម្ភដៃគូ សូមពិនិត្យមើលច្បាប់ស្តីពីការអនុវត្តន៍រដ្ឋប្បវេណី(២០១១) មាត្រា៧៨ និង មាត្រា៧៦ និងមាត្រា ៧៧ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ(១៩៨៩)។ សម្រាប់កាតព្វកិច្ចអាហារកិច្ច សូមពិនិត្យមើល មាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី (២០០៧)។

អ្នកចូលរួមជាច្រើននាក់ផ្សេងទៀតក៏បានពណ៌នាថានៅក្នុងកិច្ចព្រមព្រៀងលែងលះ (ផ្លូវការ ឬប្រពៃណី) អតីតស្វាមីរបស់ពួកគេមានកាតព្វកិច្ចបង់ថ្លៃអាហារកិច្ច ប៉ុន្តែចុងក្រោយពួកគេមិនទទួលបានការគាំទ្រឡើយ។ អ្នកចូលរួមជាច្រើនបានលើកសំណើរឲ្យកែលម្អដំណើរការទាក់ទងនឹងការបែងចែកអំណាចមេបា និងប្រាក់ឧបត្ថម្ភដៃគូ ដូចខាងក្រោម៖

*“តាមគំនិតរបស់ខ្ញុំ ដំណើរការលែងលះនៅកម្ពុជានៅមិនទាន់ល្អគ្រប់គ្រាន់ទេ... តុលាការមិនយកចិត្តទុកដាក់ ហ្មត់ចត់ចំពោះកាតព្វកិច្ចអាហារកិច្ចទេ ហើយក៏គ្មានវិធានការចាប់បង្ខំឲ្យភាគីណាមួយបង់ប្រាក់ចិញ្ចឹមកូនដែរ។ ខ្ញុំសង្ឃឹមថាតុលាការធ្វើកំណែទម្រង់ជាក់លាក់ ឬពង្រឹងការអនុវត្តន៍ច្បាប់ទាក់ទងនឹងបញ្ហានេះ” (DW17)។*

## តើអ្នកគិតថា នរណាតែងតែប្រឈមជាមួយបញ្ហាហិរញ្ញវត្ថុច្រើនជាង ក្រោយពេលលែងលះ?




ដោយសារតែការសិក្សាស្រាវជ្រាវនេះ ជាការសិក្សាបែបគុណវិស័យ ដូច្នេះវិសាលភាពទិន្នន័យសម្ភាសន៍ក៏មានកម្រិតដែរ ហើយទិន្នន័យទាំងនេះមិនបានចង្អុលបង្ហាញ ឬរកឃើញថា បុរសកម្ពុជាបានជួបប្រឈម ឬរងវិបត្តិសេដ្ឋកិច្ចក្រោយពេលលែងលះដូចដែលស្ត្រីបានជួបប្រឈមនោះទេ។ បុរសពោះម៉ាយម្នាក់បានលើកឡើងថា៖

*“បន្ទាប់ពីលែងលះ បុរសនៅតែអាចរស់នៅបានធម្មតា។ ប្រាក់រកបានមានចំនួនដដែល។ ប៉ុន្តែស្ត្រីមិនច្រើនទេដែលអាចរកប្រាក់បានច្រើនដូចបុរស... ស្ត្រីមិនក្លាហានដូចបុរសទេ ហើយមិនតាំងចិត្តខ្ពស់ក្នុងការប្រឹងប្រែង ធ្វើការ” (DM1)។*

បុរសលែងលះម្នាក់ទៀតបានពណ៌នាថាជីវិតរបស់គាត់មាន “ភាពងាយស្រួលផ្នែកហិរញ្ញវត្ថុ” ជាងមុនព្រោះពេលរៀបការ គាត់ត្រូវ "សុំការអនុញ្ញាតពីគ្នាមុននឹងចំណាយលើអ្វីមួយ" ប៉ុន្តែចាប់តាំងពីលែងលះមកវាបានក្លាយទៅជា "ងាយស្រួល សម្រាប់ខ្ញុំក្នុងការចំណាយប្រាក់ដោយមិនមានអារម្មណ៍មិនល្អឡើយ" (DM3)។ អ្នកចូលរួមមួយចំនួនបានកត់សម្គាល់ថាជារឿយៗបុរសត្រូវធ្វើការងារផ្ទះច្រើនជាងមុនបន្ទាប់ពីលែងលះ យ៉ាងហោចណាស់រហូតដល់ពួកគេរៀបការម្តងទៀត៖

*«វាពិបាកសម្រាប់អតីតស្វាមីរបស់ខ្ញុំ ព្រោះពេលយើងនៅជាមួយគ្នា ខ្ញុំជាអ្នកធ្វើការងារផ្ទះ និងធ្វើម្ហូប ប៉ុន្តែឥឡូវនេះគាត់ត្រូវតែធ្វើវា” (DW16) ។*

## ផលប៉ះពាល់វិជ្ជមាន

ដូចគ្នានឹងការឈ្វេងយល់អំពីផលប៉ះពាល់អវិជ្ជមានដែលកើតឡើងជាច្រើនឆ្នាំបន្ទាប់ពីការលែងលះគ្នានោះ បទសម្ភាសន៍ជាមួយអ្នកចូលរួមក៏បានពិភាក្សាអំពីការផ្លាស់ប្តូរវិជ្ជមានមួយចំនួនដែលពួកគេបានជួបប្រទះនៅក្នុងជីវិតប្រចាំថ្ងៃ ដែលកើតឡើងដោយសារតែការបែកបាក់អាពាហ៍ពិពាហ៍។ ស្ត្រីម្នាក់បានពណ៌នាអំពីអារម្មណ៍ថា "ដូចបានកើតម្តងទៀត" ដោយសារតែ "មិនចាំបាច់បារម្ភពីការធ្វើខុស មិនថាខ្ញុំធ្វើអ្វី ឬទៅណាទេ... ខ្ញុំអាចជាខ្លួនខ្ញុំ ខ្ញុំមិនចាំបាច់ខ្លាចអ្នកណាឡើយ" (DW11 )។

អ្នកចូលរួមម្នាក់ទៀតបានពិពណ៌នាយ៉ាងសាមញ្ញថា "សប្បាយរីករាយជាមួយនឹងជីវិតរបស់ខ្ញុំ" (DW1)។ ជាការពិតណាស់ ទិន្នន័យគុណវិស័យជាច្រើនដែលប្រមូលមកពីស្ត្រីនៅក្នុងផ្នែកនេះបង្ហាញថា ទោះបីជាការលែងលះនៅក្នុងប្រទេសកម្ពុជា បានបង្កើតឲ្យមានបញ្ហាប្រឈមយ៉ាងច្រើនដល់ស្ត្រី ការលែងលះក៏ផ្តល់នូវច្រកចេញមួយដល់ស្ត្រីជាច្រើនដើម្បីឈានទៅកាន់ជីវិតឯករាជ្យភាព សុខុមាលភាពល្អ និងសុភមង្គលល្អប្រសើរជាងមុន។



## សេរីភាពពីការបំពានផ្លូវកាយ ផ្លូវចិត្ត និង/ឬ ផ្លូវអារម្មណ៍

ស្ទើរតែគ្រប់ស្ត្រីដែលលែងលះគ្នាដែលបានចូលរួមក្នុងការសិក្សាបានរាយការណ៍ថាបានជួបប្រទះនូវការរំលោភបំពានយ៉ាងហោចមួយទម្រង់ដែលបានប្រព្រឹត្តដោយអតីតដៃគូរបស់ពួកគេ ដែលអាចជាការរំលោភបំពានផ្លូវកាយ ផ្លូវចិត្ត ឬផ្លូវចិត្ត ក្នុងអំឡុងអាពាហ៍ពិពាហ៍របស់ពួកគេ។ អវត្តមាននៃការរំលោភបំពានបែបនេះបានបង្កើតនូវផលប៉ះពាល់វិជ្ជមានដ៏ចាំបាច់សម្រាប់មនុស្សជាច្រើន។ ជាការពិតណាស់ អ្នកឆ្លើយសំណួរជាច្រើនបានរាយការណ៍ថា ការរស់នៅប្រចាំថ្ងៃរបស់ពួកគេ មានភាពស្ងប់ស្ងាត់និងអារម្មណ៍ធូរស្រាលជាងមុន ដោយពួកគេមិនចាំបាច់ស៊ូទ្រាំនឹងការឈ្លោះប្រកែកគ្នាឥតឈប់ឈរ ឬមានអារម្មណ៍ថាគ្មានសុវត្ថិភាពនៅក្នុងផ្ទះនោះទេ។ ចំណុចនេះនាំឱ្យមានភាពល្អប្រសើរច្រើនដល់សុខភាពផ្លូវចិត្ត អារម្មណ៍ និង សុខុមាលភាពទូទៅរបស់ពួកគេ។

ស្ត្រីម្នាក់បានរៀបរាប់ពីការរស់នៅដោយគ្មានការរំលោភបំពានដែលប្រព្រឹត្តដោយអតីតដៃគូរបស់នាងថា៖ "សុខភាពផ្លូវចិត្តរបស់ខ្ញុំបានប្រសើរឡើងព្រោះខ្ញុំមិនត្រូវប្រឈមជាមួយជម្លោះទៀតទេ។" អ្នកចូលរួមដដែលបានពន្យល់ថា៖ "គាត់ធ្លាប់ធ្វើបាបផ្លូវកាយខ្ញុំ ប៉ុន្តែឥឡូវខ្ញុំរស់នៅមានសុភមង្គលជាង"(DW15)។ អ្នកឆ្លើយតបម្នាក់ទៀតបានពិពណ៌នាស្រដៀងគ្នានេះដែរអំពីស្ថានភាពផ្លូវអារម្មណ៍របស់នាងថា នាងមានអារម្មណ៍ដូចត្រូវបានដោះលែងពី "ពន្ធនាគារ"៖

*"ខ្ញុំមានអារម្មណ៍ថាខ្ញុំមានសេរីភាព។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំបានរួចផុតពីភាពសោកសៅ និងទុក្ខវេទនាដែលខ្ញុំបានឆ្លងកាត់អស់ជាច្រើនឆ្នាំ ហើយបានស៊ូទ្រាំអស់រយៈពេលយ៉ាងយូរ។ ខ្ញុំមានអារម្មណ៍ថាខ្ញុំត្រូវបានដោះលែង ពីគុកងងឹតបន្ទាប់ពីការលែងលះរបស់ខ្ញុំ" (CW2) ។*

## កាត់បន្ថយបន្ទុកថែទាំគ្មានប្រាក់កម្រៃ

អ្នកចូលរួមស្ត្រីដែលលែងលះគ្នាជាច្រើនបានរៀបរាប់ថា ពួកគេលែងមានអារម្មណ៍ថាមានបន្ទុកដែលត្រូវធ្វើការងារថែទាំគ្មានប្រាក់កម្រៃប្រចាំថ្ងៃដើម្បីបំពេញតម្រូវការមូលដ្ឋានរបស់អតីតប្តីរបស់ពួកគេ។ កិច្ចការទាំងអស់នេះ រួមបញ្ចូលទាំងការងារដែលចំណាយពេលវេលាច្រើនដូចជាការចម្អិនអាហារ និងបោកគក់ខោអាវសម្រាប់អតីតស្វាមីរបស់ពួកគេ និងការមើលថែទាំសាច់ញាតិរបស់គាត់ដូចការសង្ខេប៖

"ខ្ញុំមិនចាំបាច់បារម្ភពីប្តីរបស់ខ្ញុំទេ។ ខ្ញុំមិនបាច់ព្រួយបារម្ភអំពីអ្វីដែលត្រូវចម្អិនសម្រាប់គាត់ ឬរបៀបយកចិត្តយកថ្លើមគាត់ឡើយ" (DW19)។

ស្ត្រីដែលលែងលះម្នាក់ទៀតបានពោលថា "មានរឿងវិជ្ជមានជាច្រើន [ដែលកើតចេញពី] ការលែងលះរបស់ខ្ញុំ។ ខ្ញុំមានអារម្មណ៍ធូរស្រាល និងបានរួចផុតពីស្ថានភាពមួយដែលខ្ញុំទ្រាំអស់ជាច្រើនឆ្នាំ។ ខ្ញុំមិនចាំបាច់មើលថែសាច់ញាតិគាត់ទៀតទេ" (CW4)។

ចុងក្រោយ អ្នកចូលរួមម្នាក់ទៀតបានពន្យល់ថា ចាប់តាំងពីការលែងលះរបស់នាងមក នាងលែងមានភាពតានតឹងអំពីថា "តើគាត់ត្រលប់មកផ្ទះវិញពេលណា ឬអាហារដែលគាត់ចង់ហូបជាអ្វី" ហើយឥឡូវនេះអាចរីករាយនឹងបាន "ប្រើពេលវេលាច្រើនផ្តោតលើខ្លួនឯង" (DW16)។

## បន្ទាប់ពីការលែងលះ តើនរណាជាអ្នកដែលត្រូវទទួលខុសត្រូវលើការមើលថែកូនច្រើនជាងមុន?




**៨៥% នៃអ្នកចូលរួមបានយល់ស្របថាស្ត្រីគឺជាអ្នកនកដែលត្រូវទទួលខុសត្រូវលើការមើលថែកូនច្រើនជាងមុន ធៀបនឹង ២% សម្រាប់បុរស។**

## ទំនាក់ទំនងជាមួយកូនមានភាពល្អប្រសើរ

ខណៈដែលអ្នកចូលរួមស្ត្រីជាច្រើនបានលើកឡើងពីផលប៉ះពាល់អវិជ្ជមាននៃការលែងលះមកលើកូនរបស់ពួកគេ អ្នកខ្លះក៏បានឆ្លុះបញ្ចាំងថា ទំនាក់ទំនងរបស់ពួកគេជាមួយកូនៗមានភាពល្អប្រសើរឡើង ហើយពួកគេក៏អាចធ្វើឲ្យសុខុមាលភាពរបស់កូនពួកគេមានភាពល្អប្រសើរក្នុងរយៈពេលវែងផងដែរ។ ឧទាហរណ៍ អ្នកខ្លះបានរាយការណ៍ថា ពួកគេអាចចំណាយពេលដែលមានគុណភាពជាមួយគ្នា៖ "ខ្ញុំអាចចំណាយពេលកាន់តែច្រើន និងទំនាក់ទំនងកាន់តែជិតស្និទ្ធជាមួយកូនៗ របស់ខ្ញុំ ដោយសារយើងបានបង្កើតកន្លែងសម្រាប់ការសន្ទនាបើកចំហ និងមានភាពស្មោះត្រង់ជាមួយគ្នាទៅវិញទៅមក" (CW4)។

អវត្តមាននៃការឈ្លោះប្រកែកតតឈប់ឈរនៅក្នុងផ្ទះបន្ទាប់ពីការលែងលះក៏ត្រូវបានលើកឡើងជាកត្តាវិជ្ជមានផងដែរ៖ «ខ្ញុំអាចរស់នៅដោយសេរីជាងមុន [ហើយ] ខ្ញុំមិនចាំបាច់ប្រកែកគ្នារាល់ថ្ងៃនៅចំពោះមុខកូនរបស់ខ្ញុំទេ។ ដូច្នេះវាក៏កាន់តែងាយស្រួលនិងល្អសម្រាប់គាត់ដែរ ព្រោះគាត់មិនចាំបាច់ជួបឪពុកម្តាយគាត់ឈ្លោះគ្នារាល់ថ្ងៃ» (DW12)។ ស្រដៀងគ្នា នេះដែរអ្នកឆ្លើយតបម្នាក់ទៀតបានពន្យល់ថានាងធ្លាប់គិតថា «ការលែងលះនឹងមានផលអាក្រក់សម្រាប់កូនខ្ញុំ» ដូច្នេះ «ខ្ញុំទ្រាំនៅក្នុងអាពាហ៍ពិពាហ៍របស់ខ្ញុំយ៉ាងយូរ»។ ទោះយ៉ាងណាក៏ដោយប៉ុន្មានឆ្នាំក្រោយការលែងលះ នាងបានឃើញ ថា "កូនរបស់ខ្ញុំឥឡូវនេះយល់ពីការសម្រេចចិត្ត ហើយហាក់ដូចជាសប្បាយចិត្តជាង" (CW4) ។

## ការកើនឡើងនៃស្វ័យភាពផ្ទាល់ខ្លួន

អ្នកចូលរួមស្ត្រីស្ទើរតែទាំងអស់បានពិពណ៌នាថា ការលែងលះរបស់ពួកគេបានផ្តល់ឱ្យពួកគេនូវសេរីភាពកាន់តែច្រើនក្នុងការគិតគូរ និងយកចិត្តទុកដាក់ចំពោះខ្លួនឯង។ ការផ្លាស់ប្តូរទាំងអស់នេះរាប់បញ្ចូលទាំង ការកើនឡើងនៃលទ្ធភាពសម្រេចចិត្តផ្ទាល់ខ្លួនក្នុងការរៀបចំជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ ជាមួយនឹងអារម្មណ៍នៃឯករាជ្យភាព និងស្វ័យភាពកាន់តែច្រើន។ ដូច្នេះនៅពេលសួរថា តើការលែងលះរបស់ពួកគេបាននាំឱ្យមានលទ្ធផលវិជ្ជមានណាមួយដែរ ឬទេនៅក្នុងប៉ុន្មានឆ្នាំក្រោយពីការលែងលះនោះ អ្នកចូលរួមជាច្រើនបានឆ្លើយបញ្ជាក់យ៉ាងមុតមាំដូចខាងក្រោម៖

*“ខ្ញុំមានសុខភាពផ្លូវចិត្តល្អប្រសើរជាងមុន ខ្ញុំមានសេរីភាពកាន់តែច្រើន ខ្ញុំមិនចាំបាច់បារម្ភអំពីការឈ្លោះប្រកែក ហើយខ្ញុំក៏មិនមានអារម្មណ៍តានតឹងដែរ” (DW21)។*

*“ខ្ញុំគិតថាខ្ញុំសប្បាយចិត្តជាងមុន ព្រោះខ្ញុំអាចក្លាយជាខ្លួនឯងក្រោយការលែងលះ។ ខ្ញុំមានសេរីភាព ហើយខ្ញុំមិនចាំបាច់ធ្វើពុត ឬបង្ខំខ្លួនឯងឲ្យធ្វើអ្វីដែលខ្ញុំមិនចង់ធ្វើនោះទេ» (DW10)។*

*“ខ្ញុំមានអារម្មណ៍ថាមានឯករាជ្យជាងមុន។ ខ្ញុំមានសេរីភាពច្រើនជាងមុន។ ខ្ញុំមានសុខភាពល្អជាងមុន បើគិតពីសុខភាពផ្លូវចិត្តរបស់ខ្ញុំ។ ក្នុងអំឡុងពេលរៀបការខ្ញុំត្រូវបង្ខំខ្លួនឯងឱ្យញញឹម។ បន្ទាប់ពីលែងលះ ខ្ញុំមានសេរីភាពកាន់តែច្រើន ខ្ញុំពិតជា អាចញញឹម ខ្ញុំអាចធ្វើតាមក្តីស្រមៃរបស់ខ្ញុំ និងធ្វើអ្វីដែលខ្ញុំចង់បាន។ អ្វីក៏ដោយដែលខ្ញុំចង់ធ្វើ ខ្ញុំអាចធ្វើបាន។ គ្មាននរណាឃាត់ខ្ញុំ ឬរំខានខ្ញុំរាល់ថ្ងៃឡើយ។ ខ្ញុំមានអារម្មណ៍ថាខ្ញុំបានរំដោះខ្លួនខ្ញុំចេញពីច្រវាក់» (DW20)។*

# ៥

# ការផ្លាស់ប្តូរបរិបទសង្គម...

# ៥. ការផ្លាស់ប្តូរបរិបទសង្គម...

## ការយល់ឃើញអំពីការផ្លាស់ប្តូរឥរិយាបថចំពោះការលែងលះ



*"ម្តាយក្មេកខ្ញុំធ្លាប់និយាយថា កាលពីមុនមិនសូវមានការលែងលះច្រើនទេ។ ខ្ញុំថាស្ថានភាពកាលពីអតីតកាល ខុសពីបច្ចុប្បន្នកាល វាមិនដូចគ្នាទៀតទេ។ កាលពីមុនមានអំពើហិង្សាក្នុងគ្រួសារ និងការផិតក្បត់នៅក្នុងគ្រួសារជាច្រើន ប៉ុន្តែមិនសូវមានការលែងលះគ្នាទេ ដោយសារសង្គមឱ្យតម្លៃបុរសច្រើនជាង។ ប៉ុន្តែឥឡូវនេះយើងលើកកម្ពស់សមភាពយេនឌ័រ។ ដូច្នេះស្ត្រីត្រូវស្វែងរកសេរីភាពផ្ទាល់ខ្លួន ហើយត្រូវក្រោកឈរដើម្បីខ្លួនឯង។ យើងនឹងដើរទៅមុខ មិនដើរថយក្រោយឡើយ" (DW11)។*

នៅក្នុងមូលបទចុងក្រោយ របាយការណ៍នេះនឹងត្រួតពិនិត្យដោយសង្ខេបទៅលើទស្សនៈយល់ឃើញរបស់អ្នកចូលទាំងក្នុង ចំណោមអ្នកដែលឆ្លងកាត់ការលែងលះ និងអ្នកដែលមិនធ្លាប់លែងលះដើម្បីឈ្វេងយល់ថា តើឥរិយាបថសង្គមចំពោះការលែងលះបាននឹងកំពុងផ្លាស់ប្តូរតាមបរិបទសង្គម និងតាមមនុស្សក្នុងជំនាន់ខុសគ្នាដែរឬទេ។

សក្ខីកម្ម និងបទពិសោធន៍ជាច្រើនដែលបានចែករំលែកដោយស្ត្រីដែលចូលរួមក្នុងរបាយការណ៍នេះបានបង្ហាញថា ការលែងលះនៅក្នុងប្រទេសកម្ពុជានៅតែជាជម្រើសជីវិតដ៏ចម្រូងចម្រាសមួយ ពិសេសសម្រាប់ស្ត្រី។ កម្រិតនៃភាពអាម៉ាស់ និងការមាក់ងាយចំពោះស្ត្រីដែលជ្រើសរើសអនុវត្តសិទ្ធិមូលដ្ឋាននេះបង្ហាញថា អ្នកតស៊ូមតិផ្នែកយេនឌ័រនិងភាគីពាក់ព័ន្ធដទៃទៀតត្រូវយកចិត្តទុកដាក់ជាបន្ទាន់និងត្រូវធ្វើការងារច្រើនទៀត ដើម្បីការពារសិទ្ធិស្ត្រីក្នុងការរស់នៅប្រកបដោយ សុវត្ថិភាព និងសេចក្តីថ្លៃថ្នូរទាំងមុន និងក្រោយពេលលែងលះ ហើយកំណែទម្រង់គោលនយោបាយ និងប្រព័ន្ធគ្រប់គ្រងគឺជាតម្រូវការចាំបាច់ដើម្បីសម្រួលដំណើរការលែងលះឲ្យមានភាពងាយស្រួល និងតម្លៃសមរម្យសម្រាប់ទាំងអស់គ្នា។

ទោះបីជាយ៉ាងណាក៏ដោយ ខណៈពេលដែលការលែងលះនៅតែជាជម្រើសដ៏ចម្រូងចម្រាសនោះ ទាំងអ្នកផ្តល់សម្ភាសន៍ និងអ្នកចូលរួមការស្ទង់មតិអនឡាញសម្រាប់ការសិក្សានេះបានបង្ហាញទស្សនៈច្រើនលើសលប់ថា មនុស្សជាច្រើននៅក្នុងប្រទេសកម្ពុជាបានចាត់ទុកការលែងលះជាជម្រើសធម្មតាមួយ ហើយផ្នត់គំនិតសង្គមក៏ទទួលយកការលែងលះកាន់តែច្រើនដែរ ដូចដែលក្រាហ្វខាងក្រោមបង្ហាញ។

**តើអ្នកគិតថាឥរិយាបថសង្គមមានការផ្លាស់ប្តូរដូចម្តេចខ្លះចំពោះការលែងលះ បើធៀបទៅនឹងឆ្នាំ២000?**




ដូចបានពិភាក្សាក្នុងផ្នែកខាងដើមនៃរបាយការណ៍នេះ (ជាពិសេសនៅក្នុងផ្នែកទី៤.៣) ឥរិយាបថចំពោះការលែងលះត្រូវបានរាយការណ៍ថា ទទួលរងឥទ្ធិពលនៃស្ថានភាពប្រជាសាស្ត្រ រួមទាំងទីតាំងភូមិសាស្ត្រ និងអាយុ ផងដែរ។ ឧទាហរណ៍ អ្នកចូលរួមដែលមិនធ្លាប់លែងលះម្នាក់បានពោលថាសម្រាប់នាង "ក្នុងនាមជាមនុស្សវ័យក្មេងខ្ញុំគិតថាការលែងលះជារឿងធម្មតា បើយើងរស់នៅក្នុងអាពាហ៍ពិពាហ៍មិនសប្បាយចិត្ត ហេតុអ្វីយើងត្រូវស៊ូទ្រាំ?" (NDW1)។ ទោះជាយ៉ាងណា អ្នកចូលរួមដដែលក៏បានសង្កេតឃើញថា "សម្រាប់មនុស្សជំនាន់មុនពួកគេមានការលំបាកក្នុងការទទួលយកការលែងលះ ជាជម្រើសធម្មតាមួយ។ ពួកគេនៅតែមានគំនិតវិនិច្ឆ័យចំពោះអ្នកលែងលះ ជាពិសេសស្ត្រី។"

ការឆ្លើយតបរបស់អ្នកចូលរួមបានផ្តល់នូវហេតុផលជាច្រើននៅពីក្រោយការផ្លាស់ប្តូរផ្នត់គំនិតនេះដោយ "ការយល់ឃើញក្នុងសង្គមរបស់យើងចំពោះការលែងលះបានផ្លាស់ប្តូរ ហើយយើងឃើញថាមានការទទួលយកការលែងលះច្រើនជាងមុន" (CW5)។ បុគ្គលិកអង្គការសង្គមស៊ីវិលម្នាក់បានសង្ខេបមូលហេតុនៃការផ្លាស់ប្តូរនេះ រួមមានដូចខាងក្រោម៖

*"...យុទ្ធនាការដែលបាននឹងកំពុងធ្វើឡើងជាបន្តបន្ទាប់ដោយរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលដើម្បីលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិស្ត្រី... និងអំពើហិង្សាផ្អែកលើយេនឌ័រ។ លើសពីនេះ បច្ចេកវិទ្យានិងបណ្តាញសង្គមក៏ដើរតួនាទីក្នុងការផ្សព្វផ្សាយព័ត៌មានដល់សហគមន៍ផងដែរ មនុស្សម្នាអាចមើលឃើញពីផលប៉ះពាល់អវិជ្ជមាននៃអំពើហិង្សាក្នុងគ្រួសា និងដោយដៃគូស្និទ្ធស្នាល ហើយពួកគេលែងស៊ូទ្រាំ ឬចាត់ទុកអំពើហិង្សាជារឿងធម្មតាទៀតហើយ" (CW5)។*

នៅពេលត្រូវបានសួរថា តើដំណើរការលែងលះនៅក្នុងប្រទេសកម្ពុជាគួរតែធ្វើឲ្យមានភាពងាយស្រួលជាងនេះដែរឬទេ អ្នកឆ្លើយសំណួរចំនួន ៦៨% បានយល់ស្របថា វាគួរតែត្រូវបានធ្វើឱ្យកាន់តែងាយស្រួលនិងងាយទទួលបាន ខណៈដែល ២១% បានបង្ហាញការយល់ឃើញថាដំណើរការលែងលះគួរតែរក្សានៅដដែល និង១១% បង្ហាញថាពួកគេមិនប្រាកដថាគួរ ឬមិនគួរនោះទេ។

### តើអ្នកគិតថា ដំណើរការទទួលបានការលែងលះនៅកម្ពុជាគួរតែធ្វើឲ្យស្រួលជាងនេះដែរឬទេ?




ទោះជាយ៉ាងណាលទ្ធផលស្ទង់មតិអនឡាញក៏បានបង្ហាញផងដែរថា ផ្នត់គំនិតសង្គមនៅតែមានលក្ខណៈអភិរក្សនិយម ដោយទទួលយកការលែងលះតែក្នុងកាលៈទេសៈមួយចំនួនប៉ុណ្ណោះ។ ស្ទើរតែពាក់កណ្ដាលនៃអ្នកឆ្លើយតបការស្ទង់មតិអនឡាញបង្ហាញថា ពួកគេផ្ទាល់គាំទ្រការលែងលះតែក្នុងករណីដែលពាក់ព័ន្ធនឹង "ហេតុផលធ្ងន់ធ្ងរ" ឧទាហរណ៍ ភាពមិនស្មោះត្រង់ ឬអំពើហិង្សា។

### តើអ្នកមានអារម្មណ៍ដូចម្ដេចចំពោះការលែងលះ?



ទោះជាយ៉ាងណា ទិន្នន័យសម្ភាសន៍បានបង្ហាញការព្រមព្រៀងមួយដែលថា ឥរិយាបថសង្គមចំពោះការលែងលះកំពុងតែត្រូវបានផ្លាស់ប្តូរ ហើយសកម្មភាពពង្រឹងអំណាចស្ត្រីនៅក្នុងប៉ុន្មានទសវត្សចុងក្រោយនេះគឺជាកត្តាជំរុញដ៏សំខាន់នៅពីក្រោយការផ្លាស់ប្តូរនេះ។ មនុស្សជាច្រើនបានសង្កេតឃើញថា "មនុស្សស្រីសម័យឥឡូវមិនដូចមុនទេ។ សម័យបុរាណ ស្ត្រីមានទំនោរស៊ូទ្រាំ នឹងការឈឺចាប់... ប៉ុន្តែក្នុងសម័យទំនើប ស្ត្រីមានចំណេះដឹងកាន់តែច្រើន ហើយនឹងមិនស៊ូទ្រាំនឹងអាពាហ៍ពិពាហ៍ដែលមិនសប្បាយចិត្តទៀតទេ" (DW17)។

អ្នកចូលរួមមួយចំនួនបានចែករំលែកថា តាមបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេ ផ្នត់គំនិតរបស់ពួកគេផ្ទាល់ចំពោះការលែងលះបានផ្លាស់ប្តូរតាមពេលវេលា។ អ្នកចូលរួមម្នាក់បានពន្យល់ថាខណៈពេលដែលនាង "ធ្លាប់គិតថាការលែងលះ គឺជារឿងអាក្រក់" ហើយនាងក៏ "ភ័យខ្លាចនៃការលែងលះដោយសារតែខ្ញុំខ្លាចត្រូវបានវិនិច្ឆ័យថាជាស្ត្រីដែលលែងលះគ្នា" ទស្សនៈរបស់នាងលើការលែងលះ "បានផ្លាស់ប្តូរ ហើយនាងគិតថាការលែងលះមិនមែនជារឿងអាក្រក់ទៀតនោះទេ... ប្រសិនបើអ្នកមិនអាចរួមរស់ជាមួយគ្នាបាន អ្នកគួរតែចែកផ្លូវគ្នារស់នៅរៀងខ្លួន" (DW3)។

ទោះបីជាសង្គមបានចាប់ផ្តើមយកចិត្តទុកដាក់ចំពោះស្ត្រីដែលលែងលះគ្នា តាមរយៈការផ្តល់នូវការយល់ចិត្តសេចក្តីថ្លៃថ្នូរ ស្ត្រីជាច្រើនដែលឆ្លើយតបនៅក្នុងការសិក្សានេះបានបង្ហាញថាសម្រាប់ពួកគេ គឺពួកគេមិនសម្លឹងថយក្រោយទេ។

*"[ស្ត្រីគួរ] មើលឃើញតម្លៃនៃសេរីភាព សុខភាពផ្លូវចិត្ត និងសុខុមាលភាពថាសំខាន់ជាងការស៊ូទ្រាំនឹងអាពាហ៍ពិពាហ៍ដែលហិង្សា និងមិនសប្បាយចិត្ត។ យើងគួរមានចិត្តរឹងប៉ឹងនៅពេលដែលយើងជ្រើសរើសផ្លូវជីវិតរបស់យើង យើងមិនគួរដាក់ខ្លួនយើងក្រោមសម្ពាធគ្រួសារ មិត្តភ័ក្តិ និងសហគមន៍ឡើយ។ យើងគួរតែជ្រើសរើសផ្លូវដែលយើងសប្បាយចិត្ត" (CW2)។*

# ៦

# សេចក្តីសន្និដ្ឋាន

# ៦. សេចក្តីសន្និដ្ឋាន

ការសិក្សានេះបានព្យាយាមឈ្វេងយល់អំពីការយល់ឃើញ និងបទពិសោធផ្ទាល់របស់ស្ត្រីពាក់ព័ន្ធនឹងការលែងលះនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ។ នៅក្នុងកិច្ចប្រឹងប្រែងនេះ ការសិក្សាស្រាវជ្រាវបានប្រើប្រាស់ចក្ខុវិស័យសិទ្ធិស្ត្រីដើម្បីត្រួតពិនិត្យមើលបញ្ហាសំខាន់ៗរួមមាន៖

- *កត្តាជំរុញទូទៅដែលនាំឲ្យស្ត្រីសម្រេចចិត្តលែងលះ*
- *ឧបសគ្គផ្នែកសង្គម វប្បធម៌ រដ្ឋបាល និងហិរញ្ញវត្ថុដែលស្ត្រីជួបប្រឈមនៅក្នុងដំណើរការស្វែងរកការលែងលះ*
- *ផលប៉ះពាល់រយៈពេលវែងក្រោយពីការលែងលះ – ទាំងវិជ្ជមាន និង អវិជ្ជមាន។*

ការសិក្សាបានត្រួតពិនិត្យលើបទពិសោធន៍ផ្ទាល់របស់អ្នកចូលរួមស្ត្រីដែលឆ្លងកាត់ការលែងលះគ្នា និងទស្សនៈទូទៅរបស់សាធារណៈជនទនិងអ្នកដែលមិនធ្លាប់លែងលះ។ ការសិក្សានេះប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវសកម្មផ្អែកលើគោលការណ៍លទ្ធិស្ត្រីនិយម (FPAR) ហើយការស្រាវជ្រាវនេះត្រូវបានសហការបង្កើតឡើងដោយសមាជិកសហគមន៍កម្ពុជាដែលមានបទពិសោធន៍ផ្ទាល់ទាក់ទងនឹងការលែងលះគ្នា ឬមានឪពុកម្តាយលែងលះ។

ក្រុមការងារស្រាវជ្រាវសង្ឃឹមថា ការសិក្សានេះអាចផ្តល់នូវមូលដ្ឋានភស្តុតាងបឋមសម្រាប់អ្នកតស៊ូមតិសមភាពយេនឌ័រ និងភាគីពាក់ព័ន្ធផ្សេងទៀតដើម្បីយល់កាន់តែច្បាស់អំពីនិន្នាការ និងឥរិយាបថសង្គមនាពេលបច្ចុប្បន្នជុំវិញសមភាពនៅក្នុងអាពាហ៍ពិពាហ៍ សក្តានុពលនៃទំនាក់ទំនងអំណាចដូចបង្ហាញនៅក្នុងអំឡុងពេលមានវិវាទអាពាហ៍ពិពាហ៍ និងសិទ្ធិបុគ្គល គ្រប់រូបក្នុងការចែកផ្លូវដោយសេរី ឬលែងលះប្តីឬប្រពន្ធរបស់ពួកគេ។

# ឯកសារយោង


1. Cambodian Ministry of Health & National Institute of Statistics (2023) 2021-22 Cambodia Demographic and Health Survey, online: <https://dhsprogram.com/pubs/pdf/FR377/FR377.pdf>.
2. Kann, V. Cambodian Women Vulnerable to Domestic Violence Due to Lack of Protection, Punishment, Voice of America, 16 March 2023, online: <https://www.voacambodia.com/a/cambodian-women-vulnerable-to-domestic-violence-due-to-lack-of-protection-punishment/7007647.html>.
3. Divorce on the up as women seek a way out, Phnom Penh Post, 31 October 2014, online: <https://www.phnompenhpost.com/post-weekend/divorce-women-seek-way-out>.
4. Stevenson, B., & Wolfers, J. (2006). Bargaining in the shadow of the law: Divorce laws and family distress. The Quarterly Journal of Economics, 121(1), 267-288.
5. Ibid.
6. APWLD (2018) 'Feminist Participatory Action Research (FPAR)', APWLD, online: <https://apwld.org/feminist-%20participatory-action-research-fpar/>.
7. Clarke, V., & Braun, V. (2013). Teaching thematic analysis: Overcoming challenges and developing strategies for effective learning. The psychologist, 26(2), 120-123.
8. World Health Organization (2023) Intimate Partner Violence, online: <https://apps.who.int/violence-info/intimate-partner-violence/>.
9. CDC (2023) Fast Facts: Intimate Partner Violence, online: <https://www.cdc.gov/violenceprevention/intimatepartnerviolence/fastfact.html#:~:text=Psychological%20aggression%20is%20the%20use%20of%20verbal%20and,related%20to%20serious%20health%20issues%20and%20economic%20consequences>.
10. Cambodian Law on the Prevention of Domestic Violence and Protection of Victims (2005), art. 6.
11. Brickell, K. (2014). 'Plates in a basket will rattle': Marital dissolution and home 'unmaking' in contemporary Cambodia. Geoforum, 51, 262-272.
12. Women Peace Makers (2020) 'Preserving harmony, or preventing justice? A study of local dispute resolution practices in cases of domestic and intimate partner violence in Cambodia, WPM, online: <https://wpmcambodia.org/wp-content/uploads/2020/12/Preserving-Harmony-or-Preventing-Justice_EN_2020.pdf>.
13. Brickell (2014), above n., 11.
14. Van Der Keur, D. (2014). Legal and gender issues of marriage and divorce in Cambodia. Cambodia Law and Policy Journal, 2, 1-22.
15. Ibid.
16. Ibid.

សម្រាប់ព័ត៌មានបន្ថែម៖ info@klahaan.org